# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

## សារត្ថប្បកាសិនី

## ភាគ ៣៤

## ខន្ធវារវគ្គ ឆដ្ឋភាគ

ពុទ្ធសករាជ ២៥៥៦

## អធិប្បាយ

## ខន្ធសំយុត្ត រាធសំយុត្ត ទិដ្ឋិសំយុត្ត

# អដ្ឋកថា ព្រះសុត្តន្តបិដក

## សំយុត្តនិកាយ

ឈ្មោះ

# សារត្ថប្បកាសិនី

## ភាគ ៣៤

## ខន្ធវារវគ្គ ឆដ្ឋភាគ

ពុទ្ធសករាជ ២៥៥៦

អធិប្បាយ

ខន្ធសំយុត្ត រាធសំយុត្ត ទិដ្ឋិសំយុត្ត

អដ្ឋកថាកែ ៧៣ សូត្រ

# ខន្ធវារវគ្គ

## ឆដ្ឋភាគ មាន ៣ សំយុត្ត

១-ខន្ធសំយុត្ត មាន ០៥ វគ្គ
ព្រះអដ្ឋកថាកែសេចក្តី ២១ សូត្រ

២-រាធសំយុត្ត មាន ០៤ វគ្គ
ព្រះអដ្ឋកថាកែសេចក្តី ០៩ សូត្រ

៣-ទិដ្ឋិសំយុត្ត មាន ០៤ វគ្គ និង ១០ សំយុត្ត
ព្រះអដ្ឋកថាកែសេចក្តី ៤៣ សូត្រ

រួមក្នុងឆដ្ឋភាគនេះ មាន០៣សំយុត្តធំ

ស្មើនឹង ១៣ វគ្គ និង ១០ សំយុត្ត

ព្រះអដ្ឋកថាបានកែសេចក្តីដែល

លំបាកសរុបមានចំនួន ៧៣ សូត្រ

# សារត្ថប្បកាសិនី

## អដ្ឋកថា ខន្ធវារវគ្គ

## ខន្ធសំយុត្ត ចូឡបណ្ណាសកៈ

## លេខ ៣៤

## អន្តវគ្គទី ១

## អ ដ្ឋ ក ថា

### អន្តសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង អន្តសូត្រទី ១ ដូចតទៅនេះ ៖

[១] បទថា **អន្តា** បានដល់ ចំណែកទាំងឡាយ ។ សូត្រនេះ ព្រះមានព្រះភាគត្រាស់ តាមអធ្យាស្រ័យរបស់វេនេយ្យសត្វដែលនឹងត្រាស់ដឹងបាន ដោយពាក្យថា **អន្តោ** ដោយទ្រង់ប្រកបខន្ធ ៥ ចូលនឹងអរិយសច្ច ៤ ។

ចប់អដ្ឋកថា អន្តសូត្រទី ១

# អ ដ្ឋ ក ថា

## ទុក្ខសុត្រទី ២

[៦] គប្បីជ្រាបវិនិច្ឆ័យក្នុង ទុក្ខសូត្រទី ២ ដូចតទៅនេះ ៖

សូម្បីទុក្ខសូត្រទី ២ ព្រះមានព្រះភាគ ក៏ត្រាស់ទុកតាមអជ្ឈាស្រ័យរបស់វេនេយ្យសត្វដែលនឹងត្រាស់ដឹង ដោយពាក្យថា ទុក្ខ ដោយទ្រង់ប្រកបខន្ធ ៥ ចូលនឹងអរិយសច្ច ៤ ។

ចប់អដ្ឋកថា ទុក្ខសុត្រទី២

# អ ដ្ឋ ក ថា

## សក្កាយសូត្រទី ៣

[១១] *សូម្បីសូត្រទី ៣ ក៏ដូចគ្នា គឺ ព្រះមានព្រះភាគត្រាស់ទុកតាមអធ្យាស្រ័យរបស់វេនេយ្យសត្វដែលនឹងត្រាស់ដឹងបាន ដោយពាក្យថា សក្កាយោ ដោយទ្រង់ប្រកបខន្ធ ៥ ចូលនឹងអរិយសច្ច ៤ ។*

ចប់អដ្ឋកថា សក្កាយសូត្រទី ៣

# អ ដ្ឋ ក ថា

## បរិញ្ញេយ្យសូត្រទី ៤

គប្បីជ្រាបវិនិច្ឆ័យក្នុង **បរិញ្ញេយ្យសូត្រទី ៤** ដូចតទៅនេះ ៖

[១៦] បទថា **បរិញ្ញេយ្យេ** បានដល់ ធម៌ទាំងឡាយដែលគប្បីកំណត់ដឹង គឺ គប្បីឈានកន្លង ។

បទថា **បរិញ្ញំ** បានដល់ កំណត់ដឹងដោយការឈានកន្លង ។

បទថា **បរិញ្ញាតាវី** បានដល់ បុគ្គលដែលកំណត់ដឹងច្បាស់ឈានកន្លងហើយ ដោយបរិញ្ញានោះ ។

[១៨] ព្រះមានព្រះភាគទ្រង់សម្ដែងដល់ព្រះនិព្វាន ដោយបទថា **រាគក្ខយោ** ជាដើម ។

ចប់អដ្ឋកថា បរិញ្ញេយ្យសូត្រទី៤

# អ ដ្ឋ ក ថា

## សមណសូត្រទី ៥

[២០] មិនបានអធិប្បាយទុកដោយចំពោះ ដូចក្នុងសូត្រដទៃៗ ទេ តែអធិប្បាយរួមថា “ព្រះមានព្រះភាគត្រាស់សច្ចៈ ៤ ទុក ក្នុង ៤ សូត្រ រាប់តាំងពីសូត្រទី ៥ ដល់សូត្រទី ៨” ។

ចប់អដ្ឋកថា សមណសូត្រទី៥

## ចប់អន្តវគ្គទី ១

### រួមក្នុងវគ្គនេះមាន ១០ អដ្ឋកថា

១-អដ្ឋកថា អន្តសូត្រ
២-អដ្ឋកថា ទុក្ខសូត្រ
៣-អដ្ឋកថា សក្កាយសូត្រ
៤-អដ្ឋកថា បរិញ្ញេយ្យសូត្រ
៥-អដ្ឋកថា សមណសូត្រ

# ធម្មកថិកវគ្គ

## អ ដ្ឋ ក ថា

## អវិជ្ជាសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង អវិជ្ជាសូត្រទី ១ នៃធម្មកថិកវគ្គដូចតទៅនេះ ៖*

[២៧] *បទថា ឯត្តាវតា ច អវិជ្ជាគតោ ហោតិ សេចក្តីថា ដោយហេតុដែលជាអ្នកប្រកបដោយអវិជ្ជា ព្រោះការមិនដឹងក្នុងសច្ចៈ ៤ នេះ ភិក្ខុទើបឈ្មោះថា ធ្លាក់នៅក្នុងអវិជ្ជា ។*

ចប់អដ្ឋកថា អវិជ្ជាសូត្រទី ១

# អ ដ្ឋ ក ថា

## វិជ្ជាសូត្រទី ២

[២៨] *សូម្បីក្នុង វិជ្ជាសូត្រទី ២ ក៏មានន័យដូចគ្នានេះឯង ។*

ចប់អដ្ឋកថា វិជ្ជាសូត្រទី ២

# អ ដ្ឋ ក ថា

## ធម្មកថិកសូត្រទី ៣

គប្បីជ្រាបវិនិច្ឆ័យក្នុង ធម្មកថិកសូត្រទី ៣ ដូចតទៅនេះ ៖

[២៩] ព្រះមានព្រះភាគត្រាស់ដល់ព្រះធម្មកថិក ដោយពាក្យឆ្លើយទី ១ , ត្រាស់ដល់សេក្ខភូមិ ដោយពាក្យឆ្លើយទី ២ , ត្រាស់ដល់អសេក្ខភូមិ ដោយពាក្យឆ្លើយទី ៣ ។ រួមសេចក្តីមក ព្រះមានព្រះភាគត្រាស់ភូមិ ២ អធិប្បាយព្រះធម្មកថិកឲ្យផ្សេងគ្នាដោយពាក្យសួរ ដែលភិក្ខុទូលសួរហើយ ។

ចប់អដ្ឋកថា ធម្មកថិកសូត្រទី ៣

# អ ដ្ឋ ក ថា

## ធម្មកថិកសូត្រទី ៤

[៣០] ក្នុង ធម្មកថិកសូត្រទី ៤ ព្រះមានព្រះភាគត្រាស់ការវិសជ្ជនាពាក្យសួរទាំង ៣ ទុក ៣ ប្រការ ។

ចប់អដ្ឋកថា ធម្មកថិកសូត្រទី ៤

# អ ដ្ឋ ក ថា

## ពន្ធនសូត្រទី ៥

គប្បីជ្រាបវិនិច្ឆ័យក្នុង **ពន្ធនសូត្រទី ៥** ដូចតទៅនេះ ៖

[៣១] បទថា **អតីរទស្សី** សេចក្ដីថា វដ្ដៈ ព្រះមានព្រះភាគត្រាស់ហៅថា ឆ្នេរ បុថុជ្ជនមើលមិនឃើញឆ្នេរនោះ ។

បទថា **អបារទស្សី** សេចក្ដីថា និព្វាន ព្រះមានព្រះភាគត្រាស់ហៅថា ត្រើយ បុថុជ្ជនមើលមិនឃើញត្រើយនោះ ។

បទថា **ពន្ធោ** សេចក្ដីថា (បុថុជ្ជន) ជាអ្នកជាប់ចំណងដោយកិលេស ទើប **កើត ចាស់ ស្លាប់** និងចាកលោកនេះទៅកាន់លោកដទៃ (ទាំងជាប់ចំណង) ។

ព្រះមានព្រះភាគ ត្រាស់វដ្ដទុក្ខ ទុកក្នុងសូត្រនេះឯង ។

ចប់អដ្ឋកថា ពន្ធនសូត្រទី ៥

# អ ដ្ឋ ក ថា

## បរិមុចចិត្តសូត្រទី ៦ ដល់ខ្ទបានានសូត្រទី ៩

[៣៣] *សូត្រទាំងនោះ ងាយទាំងអស់នោះឯង ។*

# អ ដ្ឋ ក ថា

## សីលសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង សីលសូត្រទី ១០ ដូចតទៅនេះ ៖*

*[៣៧] ក្នុងបទថា **អនិច្ចតោ** ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ*

*ឧបាទានក្ខន្ធ ៥ ភិក្ខុគប្បីធ្វើទុកក្នុងចិត្តថា មិនទៀង ដោយអាការដែលមានហើយត្រឡប់ជាមិនមាន (កើតហើយរលត់) គប្បីធ្វើទុកក្នុងចិត្តថា ជាទុក្ខ ដោយអាការដែលបៀតបៀន ញាំញី , គប្បីធ្វើទុកក្នុងចិត្តថា ជារោគ ព្រោះសេចក្តីថា ឈឺចាប់ , គប្បីធ្វើទុកក្នុងចិត្តថា ជាបូស ព្រោះសេចក្តីថា ស្អុយខាងក្នុង , គប្បីធ្វើទុកក្នុងចិត្តថា មុត (មុតដោយសរ) ព្រោះជាបច្ច័យដល់បូសទាំងនោះ ឬព្រោះមានន័យថា ជីក , គប្បីធ្វើទុកក្នុងចិត្តថា លំបាក ព្រោះអត្ថថាទុក្ខ , គប្បីធ្វើទុកក្នុងចិត្តថា ជាអ្នកបៀតបៀន ព្រោះអត្ថថា ជាបច្ច័យឲ្យកើតអាពាធ ដែលមានមហាភូតរូបដែលជាវិសភាគគ្នាជាសមុដ្ឋាន គប្បីធ្វើទុកក្នុងចិត្តថា ជារបស់ដទៃ ព្រោះអត្ថថា មិនមែនរបស់ខ្លួន , គប្បីធ្វើទុកក្នុងចិត្តថា ទ្រុឌទ្រោម ព្រោះអត្ថថា គ្រាំគ្រា , គប្បីធ្វើទុកក្នុងចិត្តថា សូន្យ ព្រោះអត្ថថា សូន្យបាកសត្វ , គប្បីធ្វើទុកក្នុងចិត្តថា ជាអនត្តា ព្រោះ*

មិនមានអត្តា ។

ក្នុងទីនេះ គប្បីជ្រាបសេចក្តីអធិប្បាយបន្ថែមយ៉ាងនេះថា ព្រះមានព្រះភាគត្រាស់ដល់ការធ្វើទុកក្នុងចិត្តថា មិនទៀង ដោយពីរបទថា **អនិច្ចតោ បលោកតោ** (មិនទៀង , បែកធ្លាយ) ត្រាស់ដល់ការធ្វើទុកក្នុងចិត្តថាជាអនត្តា ដោយពីរបទថា **សុញ្ញតោ អនត្តតោ** (សូន្យ , ជាអនត្តា) ត្រាស់ដល់ការធ្វើទុកក្នុងចិត្តថា ជាទុក្ខ ដោយបទដ៏សេស ។ បទដ៏សេសក្នុងព្រះសូត្រនេះ មានអត្ថងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា សីលសូត្រទី ១០

# អ ដ្ឋ ក ថា

## សុតវាសូត្រទី ១១

[៤២] ក្នុង *សុតវាសូត្រទី ១១* ក៏ដូចគ្នា គឺ មានអត្ថងាយនោះឯង ។ ប៉ុន្តែថា ក្នុងសូត្រទី ១០ ព្រះមានព្រះភាគត្រាស់ **បារិសុទ្ធិសីល** ទុកដោយបទថា **សីលវតា** ។ ក្នុងសូត្រទី ១១ នេះ ត្រាស់កម្មដ្ឋានទុក ដោយបទថា **សុតវតា** នេះជាសេចក្តីដែលផ្សេងគ្នា ។

ចប់អដ្ឋកថា សុតវាសូត្រទី ១១

# អ ដ្ឋ ក ថា

## កប្បសូត្រទី ១២

[៤៥] *កប្បសូត្រទី ១២ (មានសេចក្តី) ដូចរាហុលោវាទសូត្រទាំងឯង ៗ*

ចប់អដ្ឋកថា កប្បសូត្រទី ១២

# អ ដ្ឋ ក ថា

## កប្បសូត្រទី ១៣

[៤៦] *កប្បសូត្រទី ១៣ (មានសេចក្តី) ដូចរាហុលោវាទសូត្រទាំងឯង ។*

ចប់អដ្ឋកថា កប្បសូត្រទី ១៣

## ចប់ធម្មកថិកវគ្គទី ២

### រួមក្នុងវគ្គនេះមាន ១១ អដ្ឋកថា

១-អដ្ឋកថា អវិជ្ជាសូត្រ
២-អដ្ឋកថា វិជ្ជាសូត្រ
៣-អដ្ឋកថា ធម្មកថិកសូត្រទី ១
៤-អដ្ឋកថា ធម្មកថិកសូត្រទី ២
៥-អដ្ឋកថា ពន្ធនសូត្រ
៦-អដ្ឋកថា បរិមុចចិត្តសូត្រទី ១
៧-អដ្ឋកថា បរិមុចចិត្តសូត្រទី ២
៨-អដ្ឋកថា សីលសូត្រ
៩-អដ្ឋកថា សុត្វាសូត្រ
១០-អដ្ឋកថា កប្បសូត្រទី ១
១១-អដ្ឋកថា កប្បសូត្រទី ២

# អវិជ្ជាវគ្គទី ៣

## អ ដ្ឋ ក ថា

### សមុទយធម្មសូត្រទី ១

[៤៧-៦០] *អដ្ឋកថាសូត្រទី ១ ដល់សូត្រទី ១០ ផ្តើមដោយសមុទយធម្មសូត្រ ក្នុងអវិជ្ជាវគ្គ មានអត្ថងាយទាំងអស់ ។ ក៏ក្នុងវគ្គនេះ ព្រះមានព្រះភាគ ត្រាស់សច្ចៈ ៤ ទុកក្នុងគ្រប់ៗ សូត្រ (គឺពីសូត្រទី ១ ដល់សូត្រទី ១០) នោះឯង ។*

**ចប់អវិជ្ជាវគ្គទី ៣**

**ក្នុងវគ្គនេះ មិនមានអដ្ឋកថា**

**ជួយកែសេចក្តីឡើយ ។**

# កុក្កុឡវគ្គទី ៤

## អ ដ្ឋ ក ថា

## កុក្កុឡសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យក្នុង កុក្កុឡសូត្រទី ១ នៃកុក្កុឡវគ្គ ដូចតទៅនេះ ៖*

[៦១] *បទថា កុក្កុឡំ ប្រែថា ក្តៅ គឺ ឆេះដោយភ្លើង ។ ក្នុងសូត្រនេះ ព្រះមានព្រះភាគ ត្រាស់លក្ខណៈរបស់ទុក្ខ ដែលមានសភាពក្តៅ ទុកដូចជាគំនរផេះ ។*

*ក្នុងសូត្រដ៏សេស ព្រះមានព្រះភាគត្រាស់ចែកលក្ខណៈទាំងអស់នេះមានអនិច្ចលក្ខណៈជាដើម ទុកតាមអជ្ឈាស្រ័យរបស់បុគ្គលនោះឯង ។*

## ចប់កុក្កុឡវគ្គទី ៤

# ទិដ្ឋិវគ្គទី ៥

## អ ដ្ឋ ក ថា

## អជ្ឈត្តិកសូត្រទី ១

[៧៣] *សូត្រទី ១ ពាក្យថា កឹ ឧបាទាយ បានដល់ ព្រោះអាស្រ័យអ្វី ។*

ចប់អដ្ឋកថា អជ្ឈត្តិកសូត្រទី ១

# អ ដ្ឋ ក ថា

## ឯតំមមសុត្រទី ២

[៧៥] ក្នុងសូត្រទី ២ ពាក្យថា កឹ **អភិនិវិស្ស** បានដល់ ព្រោះប្រកាន់អ្វី អធិប្បាយថា ធ្វើឲ្យជាបច្ច័យ ។

ចប់អដ្ឋកថា ឯតំមមសូត្រទី ២

# អ ដ្ឋ ក ថា

## ឯសោអត្តសូត្រទី ៣

[៧៧] *ក្នុងសូត្រទី ៣ ជាដើម ពាក្យថា ទិដ្ឋិ ជាដើម ព្រះមានព្រះភាគត្រាស់ តាមអជ្ឈាស្រ័យរបស់បុគ្គល ។*

ចប់អដ្ឋកថា ឯសោអត្តសូត្រទី ៣

# អ ដ្ឋ ក ថា

## អានន្ទសូត្រទី ១០

[៩១] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ឧបសង្កមិ** ក្នុងអានន្ទសូត្រទី ១០ ។ ព្រះអានន្ទត្ថេរឃើញពួកភិក្ខុដទៃ ក៏ញុំាងព្រះសាស្ដាដើម្បីប្រទាននូវកម្មដ្ឋាន គឺ ខន្ធ ៥ ប្រកបហើយ ក៏សម្រេចព្រះអរហន្ត ទើបព្យាករណ៍ព្រះអរហត្តក្នុងសំណាក់ព្រះសាស្ដា ទើបគិតថា សូម្បីយើងក៏នឹងញុំាងព្រះសាស្ដាឲ្យត្រាស់ប្រទានកម្មដ្ឋាន គឺ ខន្ធ ៥ ប្រកបហើយ ក៏សម្រេចព្រះអរហត្ត នឹងព្យាករណ៍ព្រះអរហន្ត ដូច្នេះ ទើបចូលទៅគាល់ ។

ឯព្រះសាស្ដាសូម្បីទ្រង់មិនឃើញការលះកិលេសទាំងឡាយ ដែលមគ្គខាងលើបីគប្បីសម្លាប់របស់ព្រះថេរៈ ក្នុងវេលាដែលព្រះអង្គទ្រង់មានព្រះជន្មនៅ ក៏ត្រាស់ប្រាប់ដោយព្រះតម្រិះថា តថាគតនឹងកំណត់មើលចិត្តរបស់ភិក្ខុនេះ ។ ក៏ចិត្តរបស់ព្រះថេរៈនោះបានស្ដាប់ហើយ មនសិការព្រះ-កម្មដ្ឋានលើកទីមួយ ឬលើកទីពីរ តែប្រព្រឹត្តទៅដោយគិតថា វេលានេះជាវេលាឧបដ្ឋាកដល់ព្រះសម្ពុទ្ធ ។ ព្រះអានន្ទត្ថេរនោះ មានធម៌ជាគ្រឿង

អប់រំនូវវិមុត្តិ ហើយញ៉ាំងចិត្តរបស់ខ្លួនឲ្យរីករាយ ជាបុគ្គលប្រកបរឿយៗ ក្នុងព្រះកម្មដ្ឋាន នឹងបានសម្រេច ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា អានន្ទសូត្រទី ១០

## ចប់ទិដ្ឋិវគ្គទី ៥

### រួមក្នុងវគ្គនេះមាន ០៤ អដ្ឋកថា

១-អដ្ឋកថា អជ្ឈត្តិកសូត្រ
២-អដ្ឋកថា ឯតំមមសូត្រ
៣-អដ្ឋកថា ឯសោអត្តសូត្រទី១
១០-អដ្ឋកថា អានន្ទសូត្រ

**ចូឡបណ្ណាសកៈ រួមមាន ៥ វគ្គ**

**គឺ**

**អត្តវគ្គ . ធម្មកថិកវគ្គ . អវិជ្ជាវគ្គ . កុក្កុឡវគ្គ . ទិដ្ឋិវគ្គ**

## ចប់បណ្ណាសកៈដែលមានក្នុងខន្ធសំយុត្ត ៣ បណ្ណាសកៈ

# រាធសំយុត្ត

## បឋមវគ្គ

## អ ដ្ឋ ក ថា

### មារសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង មារសូត្រទី ១ ដូចតទៅនេះ ៖

[៩៣] បទថា មារោ វា អស្ស សេចក្តីថា សេចក្តីស្លាប់គប្បីមាន ។

បទថា មារេតា វា សេចក្តីថា ឬសត្វអ្នកត្រូវសម្លាប់ (គប្បីមាន) ។

បទថា យោ វា បន មិយ្យតិ សេចក្តីថា ឬថា អ្នកណាស្លាប់ ។

បទថា និព្វិទត្ថំ បានដល់ ដើម្បីនិព្វិទាញាណ ។

បទថា និព្វានត្ថា សេចក្តីថា ឈ្មោះថា ផលវិមុត្តិនេះ មានអនុបាទា-និព្វានជាផល អធិប្បាយថា ដើម្បីអនុបាទានិព្វាន ។

បទថា អច្ចសរា សេចក្តីថា អ្នកប្រព្រឹត្តកន្លង គឺ សួរហួសបញ្ហាហើយ ។

បទថា និព្វានោគធំ សេចក្តីថា តាំងនៅក្នុងនិព្វាន អធិប្បាយថា

ឈ្មោះថា មគ្គព្រហ្មចរិយៈរមែងនាំចូលទៅកាន់និព្វាន មិនកន្ទុំងអំពីនិព្វាន ឡើយ ។

បទថា **និព្វានបរិយោសានំ** សេចក្ដីថា និព្វានជាទីបំផុត គឺ ជាផល សម្រេច បានដល់ ជាទីបញ្ចប់នៃមគ្គព្រហ្មចរិយៈនោះ ។

ចប់អដ្ឋកថា មារសូត្រទី ១

# អ ដ្ឋ ក ថា

## សត្តសូត្រទី ២

គប្បីជ្រាបវិនិច្ឆ័យក្នុង សត្តសូត្រទី ២ ដូចតទៅនេះ ៖

[៩៤] បទថា **សត្តោ** ជាពាក្យសួរដល់បុគ្គល ។

បទថា **តត្រ សត្តោ តត្រ វិសត្តោ** សេចក្តីថា អ្នកជាប់ គឺ អ្នកជាប់ជំពាក់នៅក្នុងឧបាទានក្ខន្ធនោះ ។

បទថា **បំសុាគារកេហិ** ប្រែថា កូនផ្ទះដែលធ្វើដោយអាចម៍ដី ។

បទថា **កេឡាយន្តិ** ប្រែថា លេង ។

បទថា **ធនាយន្តិ** ប្រែថា សម្គាល់កូនផ្ទះដែលធ្វើដោយអាចម៍ដីថាដូចជាទ្រព្យ ។

បទថា **មមាយន្តិ** បានដល់ ធ្វើការប្រកាន់ថា នេះរបស់យើង នេះរបស់យើង គឺ មិនព្រមសូម្បីឲ្យអ្នកដទៃប៉ះពាល់ ។

បទថា **វិកីឡនិកំ ករោន្តិ** សេចក្តីថា ក្មេងប្រុស ឬក្មេងស្រីទាំងនោះគិតថា ការលេងរួចហើយ ទើបឈូសចោលធ្វើឲ្យលេងមិនកើត ។

ចប់អដ្ឋកថា សត្តសូត្រទី ២

# អ ដ្ឋ ក ថា

## ភវនេត្តិសូត្រទី ៣

*គប្បីជ្រាបវិនិច្ឆ័យក្នុង **ភវនេត្តិសូត្រទី ៣** ដូចតទៅនេះ ៖*

[៩៥] *បទថា **ភវនេត្តិ** បានដល់ តណ្ហា ដូចខ្សែបងសត្វទុកក្នុងភព ។*

ចប់អដ្ឋកថា ភវនេត្តិសូត្រទី ៣

# អ ដ្ឋ ក ថា

## បរិញ្ញេយ្យសូត្រទី ៤

[៩៦] *សូត្រទី ៤ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា បរិញ្ញេយ្យសូត្រទី ៤

# អ ដ្ឋ ក ថា

## បឋមសមណព្រាហ្មណសូត្រទី ៥

[៥៧] *ព្រះមានព្រះភាគត្រាស់សច្ចៈ ៤ ទុកក្នុង ៤ សូត្រ មាន បឋមសមណព្រាហ្មណសូត្រទី ៥ ជាដើម (និង) ត្រាស់ការលះបង់កិលេស ទុកក្នុង ២ សូត្រ នោះឯង ។*

ចប់អដ្ឋកថា បឋមសមណព្រាហ្មណសូត្រទី ៥

## ចប់បឋមវគ្គទី ១

### រួមក្នុងវគ្គនេះមាន ០៥ អដ្ឋកថា

១-អដ្ឋកថា មារសូត្រ ២-អដ្ឋកថា មារធម្មសូត្រ

៣-អដ្ឋកថា ភវនេត្តិសូត្រ ៤-អដ្ឋកថា បរិញ្ញេយ្យសូត្រ

៥-អដ្ឋកថា បឋមសមណព្រាហ្មណសូត្រជាដើម....

# ទុតិយវគ្គ

## អ ដ្ឋ ក ថា

### មារសូត្រទី ១

[១០៤] ក្នុង *មារសូត្រទី ១ នៃ ទុតិយវគ្គទី ២ ដោយពាក្យថា មារ* ព្រះរាធត្ថេរ រមែងទូលសួរដល់សេចក្តីស្លាប់ ។ សេចក្តីថា ក៏ព្រោះឈ្មោះថា សេចក្តីស្លាប់ដែលផុតចាកខន្ធ មានរូបជាដើមមិនមាន ។ ហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ដល់ព្រះថេរៈ មានជាដើមថា " ម្នាលរាធៈ រូបនេះឯងជាមារ " ។

ចប់អដ្ឋកថា មារសូត្រទី ១

# អ ដ្ឋ ក ថា

## មារធម្មសូត្រទី ២

[១០៥] ក្នុងសូត្រទី ២ ពាក្យថា មារធម្មំ បានដល់ មរណធម្មំ ។ អត្ថទាំងពួងគប្បីជ្រាបដោយឧបាយនេះ ដូច្នេះ ។

ចប់អដ្ឋកថា មារធម្មសូត្រទី ២

## ចប់ទុតិយវគ្គទី ២

### រួមក្នុងវគ្គនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា មារសូត្រ ២-អដ្ឋកថា មារធម្មសូត្រ

# អ ដ្ឋ ក ថា

## អាយាចនវគ្គទី ៣

[១១៦] សេចក្ដីតទៅនេះ ឆាយទាំងអស់នោះឯង ។ ពិតណាស់ ព្រះរាជគ្រូវនេះ ឈ្មោះថា ជាព្រះថេរៈដែលឈ្លាសវៃ ។ ព្រោះទ្រង់ទតឃើញព្រះថេរៈនេះ ហេតុការណ៍ដ៏ល្អិត ទើបប្រាកដដល់ព្រះមានព្រះភាគ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់សម្ដែងធម៌ដល់ព្រះរាជៈនោះ ដោយន័យផ្សេងៗ ។ ដូច្នេះ ក្នុងរាជសំយុត្តនេះ ២ វគ្គខាងដើម ព្រះមានព្រះភាគ ទ្រង់សម្ដែងទុកដោយអំណាចការសួរ ។

វគ្គទី ៣ ព្រះមានព្រះភាគ ត្រាស់ដោយអំណាចការទូលសូម ។

ចប់អដ្ឋកថា អាយាចនវគ្គទី ៣

## ចប់អាយាចនវគ្គទី ៣

### រួមក្នុងវគ្គនេះមាន ០១ អដ្ឋកថា

១-អដ្ឋកថា គឺ អាយាចនវគ្គទី៣

# ឧបនិសិន្នវគ្គទី ៤

## អ ដ្ឋ ក ថា

### វគ្គទី ៤

[១២៨] *ព្រះមានព្រះភាគត្រាស់ដោយអំណាចឧបនិសិន្នកថា ។ តែថា រាធសំយុត្តនេះសូម្បីទាំងអស់ គប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់ធ្វើដោយអំណាចធម៌ជាគ្រឿងអប់រំវិមុត្តិដល់ព្រះថេរៈ ។*

ចប់អដ្ឋកថា ឧបនិសិន្នវគ្គទី ៤

**ចប់ឧបនិសិន្នវគ្គទី ៤**

**រួមក្នុងវគ្គនេះមាន ០១ អដ្ឋកថា**

១-អដ្ឋកថា គឺ ឧបនិសិន្នវគ្គទី៤

# ទិដ្ឋិសំយុត្ត

## សោតាបត្តិវគ្គទី ១

## អ ដ្ឋ ក ថា

### វាតសូត្រទី ១

[១៨៤] *គប្បីជ្រាបវិនិច្ឆ័យក្នុង* ***ទិដ្ឋិសំយុត្ត*** *ដូចតទៅនេះ ៖*

*ក្នុងបទថា* ***ន វាតា វាយន្តិ*** *ជាដើម មានអធិប្បាយថា បានឮថា ជនទាំងនោះ មានការឃើញយ៉ាងនេះថា ខ្យល់ដែលបក់បំបាក់មែកឈើជាដើម មិនមែនខ្យល់ (ដែលពិត) នោះ ឈ្មោះថា ជាលេស (អាការ) របស់ខ្យល់ ចំណែកខ្យល់ ក៏តាំងនៅមាំដូចសសរគោល និងដូចកំពូលភ្នំ ។*

*មួយវិញទៀត ទឹកស្ទឹងដែលហូរនាំស្មៅ និងឈើជាដើម នោះមិនមែនទឹកហូរ ជាលេស (អាការ) របស់ទឹក ចំណែកទឹក ក៏តាំងនៅមាំដូចសសរ-គោល និងដូចកំពូលភ្នំ ។*

ម្យ៉ាងទៀត ស្ត្រីមានគភ៌ពួកណា ដែលនាំគ្នាពោលថា សម្រាលកូន ស្ត្រីទាំងនោះ សូម្បីនឹងមានផ្ទៃសម្រាលហើយក៏ពិត តែក៏មិនឈ្មោះថា គភ៌ (របស់ស្រីទាំងនោះ) នឹងសម្រាលមក នោះឈ្មោះថា ជាលេស (អាការ) របស់គភ៌ ចំណែកគភ៌ ក៏តាំងនៅមាំដូចសសរគោល និងដូចកំពូលភ្នំ ។

ម្យ៉ាងទៀត ព្រះចន្ទ និងព្រះអាទិត្យ រះ ឬលិច ក៏មិនឈ្មោះថា រះ (ពិត) មិនឈ្មោះថា លិច (ពិត) នោះឈ្មោះថា ជាលេស (អាការ) របស់ព្រះចន្ទ និងព្រះអាទិត្យ , ចំណែកព្រះចន្ទ និងព្រះអាទិត្យ ក៏តាំងនៅមាំដូចសសរគោល និងដូចកំពូលភ្នំ ។

ចប់អដ្ឋកថា វាតសូត្រទី ១

# អ ដ្ឋ ក ថា

## ឯតំមមសូត្រទី ២ ដល់ នោចមេសិយាសូត្រទី ៤

[១៤៩] ក្នុងបទថា ទិដ្ឋំ ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

អារម្មណ៍ដែលឃើញបាន (ទិដ្ឋំ) បានដល់ រូបាយតនៈ , អារម្មណ៍ដែលបានឮ (សុតំ) បានដល់ សទ្ទាយតនៈ , អារម្មណ៍ដែលបានជ្រាប (មុតំ) បានដល់ គន្ធាយតនៈ រសាយតនៈ (និង) ផោដ្ឋព្វាយតនៈ ។ ក៏គន្ធាយតនៈ រសាយតនៈ (និង) ផោដ្ឋព្វាយតនៈ នុ៎ះហៅថា អារម្មណ៍ដែលបានជ្រាប (មុតំ) ព្រោះត្រូវ (ឲ្យ) មកដល់ (បសាទរូប) មុន ទើបនឹងទទួលបាន ។ អាយតនៈ ៧ ដ៏សេស ឈ្មោះថា វិញ្ញាតំ ។

បទថា **បត្តំ** បានដល់ អារម្មណ៍ដែលស្វែងរក ឬមិនស្វែងរកក៏ដោយ (តែ) បានប្រសព្វ ។

បទថា **បរិយេសិតំ** បានដល់ អារម្មណ៍ដែលស្វែងរកហើយ ដែលមកជួបប្រសព្វ ឬមិនជួបប្រសព្វក៏ដោយ ។

បទថា **អនុវិចរិតំ មនសា** បានដល់ អារម្មណ៍ដែលចិត្តតាមពិចារណាហើយ ។

ពិតណាស់ អារម្មណ៍ក្នុងលោក ស្វែងរកហើយ ទើបជួបក៏មាន ស្វែងរកហើយតែមិនជួបក៏មាន មិនបានស្វែងរកតែជួបក៏មាន មិនបានស្វែងរកហើយមិនបានជួបក៏មាន ។

ម្យ៉ាងទៀត អារម្មណ៍ដែលស្វែងរកហើយជួបខ្លះ ដែលមិនបានស្វែងរកតែជួបខ្លះ ឈ្មោះថា **បត្ត** ព្រោះដោយអត្ថថា ជួបហើយ អារម្មណ៍ដែលស្វែងរកហើយតែមិនជួប ឈ្មោះថា **បរិយេសិត** (អារម្មណ៍ដែលស្វែងរកហើយ) អារម្មណ៍ដែលមិនបានស្វែងរកមិនបានជួប ឈ្មោះថា **មនសានុចរិតំ** (តាមពិចារណាដោយចិត្ត) ឬថា អារម្មណ៍ទាំងអស់នេះ ឈ្មោះថា តាមពិចារណាដោយចិត្តនោះឯង ។

ចប់អដ្ឋកថាសូត្រទី ២ ដល់ សូត្រទី ៤

# អ ដ្ឋ ក ថា

## នត្ថិទិន្នសូត្រទី ៥

[១៥២] ក្នុងបទថា **នត្ថិ ទិន្នំ** ជាដើម មានអធិប្បាយដូចតទៅនេះ ៖

ដោយបទថា **នត្ថិ ទិន្នំ** បុគ្គលដែលជាមិច្ឆាទិដ្ឋិទាំងឡាយ ពោលថា ទានដែលឲ្យហើយមិនមានផល ។

ការបូជាធំ ហៅថា **យិដ្ឋំ** ។ ក្នុងបទថា **ហុតំ** ព្រះមានព្រះភាគទ្រង់បំណងយកលាភសក្ការៈច្រើន ។ បុគ្គលជាមិច្ឆាទិដ្ឋិទាំងឡាយ បដិសេធបុញ្ញកម្មទាំងពីរយ៉ាងនោះ ដោយសំដៅយកថា មិនមានផលឡើយ ។

បទថា **សុកតទុក្កដានំ** បានដល់ នៃកម្មដែលធ្វើល្អ និងធ្វើអាក្រក់ អធិប្បាយថា នៃកុសលកម្ម និងអកុសលកម្មទាំងឡាយ ។

បទថា **ផលំ វិបាកោ** សេចក្តីថា វត្ថុណាដែលហៅថា ផល ឬវិបាក បុគ្គលដែលជាមិច្ឆាទិដ្ឋិ រមែងពោលវត្ថុនោះថា មិនមាន ។

បទថា **នត្ថិ អយំ លោកោ** សេចក្តីថា លោកនេះសម្រាប់អ្នកនៅក្នុងបរលោក មិនមាន ។

បទថា **បរលោកោ** សេចក្តីថា លោកដទៃ សម្រាប់អ្នកដែលនៅក្នុង

លោកនេះ ក៏មិនមាន ។ ឧច្ឆេទវាទីបុគ្គល រមែងសម្តែងថា សព្វសត្វរមែងដាច់សូន្យ ក្នុងលោកនោះៗ ឯង ។

ឧច្ឆេទវាទីបុគ្គលពោលថា **នត្ថិ មាតា នត្ថិ បិតា** (មាតាមិនមាន បិតាមិនមាន) ដូច្នេះ ព្រោះ (គេប្រកាន់ថា) មិនមានផល ការបដិបត្តិត្រូវ និងការបដិបត្តិខុសក្នុងមាតាបិតាទាំងនោះ ។

ឧច្ឆេទវាទីបុគ្គលពោលថា **នត្ថិ សត្តា ឱបបាតិកា** (សត្វទាំងឡាយជាឱបបាតិកៈមិនមាន) ដូច្នេះ ព្រោះជឿថា ឈ្មោះថា សត្វដែលចុតិហើយ និងឧប្បត្តិឡើង (ទៀត) មិនមាន ។

បទថា **ចាតុម្មហាភូតិកោ** សេចក្តីថា កើតមកពីមហាភូតរូប ៤ ។

បទថា **បថវី បថវីកាយំ** បានដល់ បឋវីធាតុខាងក្នុង (ទៅជា) បឋវីធាតុខាងក្រៅ ។

បទថា **អនុបេតិ** ប្រែថា ចូលដល់ ។ បទថា **អនុបគច្ឆតិ** ជាវេវចនៈរបស់បទថា **អនុបេតិ** នោះឯង ។ មានន័យថា ជ្រាបចូលទៅ ដូច្នេះខ្លះ ។

ដោយបទសូម្បីទាំងពីរ បុគ្គលជាមិច្ឆាទិដ្ឋិ រមែងសម្តែងថា ចូលដល់ គឺ ចូលទៅដល់ ។ ក្នុងធាតុដ៏សេស មានអាបោជាដើម ក៏មានន័យដូចគ្នានេះឯង ។

បទថា **ឥន្ទ្រិយានិ** សេចក្តីថា ឥន្ទ្រិយទាំងឡាយមានចិត្តជាទី ៦ រមែងអណ្តែតទៅកាន់អាកាស ។

បទថា **អាសន្ទិបញ្ចមា** សេចក្តីថា (បុរស ៤ នាក់) និងទាំងគ្រែដែល (បុគ្គលស្លាប់) ដេក ជាទី ៥ ។ អធិប្បាយថា គ្រែ និងបុរស ៤ នាក់ ដែលឈរសែងគ្រែជើង ៤ ។

បទថា **យាវ អាឡាហនា** ប្រែថា រហូតដល់ព្រៃជាទីចោលសាកសព ។

បទថា **បទានិ** សេចក្តីថា ស្នាមជើង គឺ គុណ សេចក្តីល្អ (និងសេចក្តីអាក្រក់) ដែលប្រព្រឹត្តទៅ ដោយមានជាដើមថា បុគ្គលនេះជាអ្នកមានសីលល្អយ៉ាងនេះ បុគ្គលនេះ ជាអ្នកទ្រុស្តសីលយ៉ាងនេះ ។

ម្យ៉ាងទៀត រាងកាយនុ៎ះឯង លោកបំណងថា ស្នាមជើងក្នុងទីនេះ ។

បទថា **កាបោតកានិ** ប្រែថា មានពណ៌ដូចសត្វព្រាប អធិប្បាយថា មានពណ៌ដូចស្លាបព្រាប ។

បទថា **ភស្សន្តា** គឺ **ភស្មន្តា** (ប្រែថា មានផេះជាទីបំផុត) ម្យ៉ាងទៀត **ភស្មន្តា** នេះឯង គឺជាបាលី (ដើម) ។

បទថា **អាហុតិយោ** សេចក្តីថា ទានដែលបុគ្គលឲ្យហើយ ចែកប្រភេទជារបស់ទទួលភ្ញៀវ និងគ្រឿងសក្ការៈជាដើម ទាំងអស់សុទ្ធតែមានផេះជាទី

បំផុតនោះឯង មិនមានផលក្រៃលែងជាងនោះទេ ។

បទថា **ទត្តុបញ្ញត្តមិទំ** គឺ ទាន ពួកបុគ្គលល្ងង់បញ្ញត្តិទុក ។ មានពាក្យអធិប្បាយដូច្នេះថា ពួកមិច្ឆាទិដ្ឋិសម្តែងថា ទាននេះ ពួកបុគ្គលល្ងង់ គឺ បុគ្គលមិនដឹងបញ្ញត្តិទុក មិនមែនបុគ្គលឆ្លាតបញ្ញត្តិទុកទេ បុគ្គលល្ងង់ឲ្យ (ទាន) បុគ្គលឆ្លាតទទួល (ទាន) ។

ចប់អដ្ឋកថា នត្ថិទិន្នសូត្រទី ៥

# អ ដ្ឋ ក ថា

## ករោតោសូត្រទី ៦១

[១៥៤] បទថា **ករតោ**[១] គឺ ធ្វើដោយដៃរបស់ខ្លួនឯង ។

បទថា **ការយតោ** គឺ ឲ្យគេធ្វើតាមពាក្យបង្គាប់ (ប្រើឲ្យធ្វើ) ។

បទថា **ឆិន្ទតោ** គឺ កាត់អវយវៈទាំងឡាយ មានដៃជាដើម របស់បុគ្គលដទៃ ។

បទថា **ឆេទាបយតោ** គឺ បៀតបៀនដោយអាជ្ញា ។

បទថា **សោចតោ** សេចក្ដីថា ធ្វើសេចក្ដីសោកដល់បុគ្គលដទៃដោយខ្លួនឯងក្ដី ប្រើឲ្យអ្នកដទៃធ្វើក្ដី ដោយទុច្ចរិតកម្ម មានលួចរបស់បុគ្គលដទៃជាដើម ។

បទថា **កិលមតោ** សេចក្ដីថា ធ្វើខ្លួនឯងឲ្យលំបាកក្ដី ធ្វើអ្នកដទៃឲ្យលំបាកក្ដី ដោយការបង្អត់អាហារ និងការបង្ខាំងក្នុងគុកជាដើម ។

បទថា **ផន្ទតោ ផន្ទាបយតោ** សេចក្ដីថា ក្នុងវេលាបៀតបៀនបុគ្គលដទៃដែលក្ដៅក្រហាយហើយ ឈ្មោះថា ទាំងធ្វើខ្លួនឯងឲ្យក្ដៅក្រហាយ ទាំងធ្វើឲ្យបុគ្គលដទៃសូម្បីនោះក្ដៅក្រហាយផង ។

---

១ បាលីជា ករតោ ។

បទថា **បាណមតិបាតាបយតោ** សេចក្តីថា សម្លាប់សត្វខ្លួនឯងក្តី ប្រើឲ្យអ្នកដទៃសម្លាប់ក្តី ។

ក្នុងគ្រប់ៗ បទ ក៏គប្បីជ្រាបន័យ ដោយអំណាចហេតុនៃការធ្វើយ៉ាងនេះឯង ។

បទថា **សន្ធឹ** បានដល់ ទី.តរបស់ផ្ទះ ។

បទថា **និល្លោបំ** បានដល់ ប្លន់អ្នកស្រុក ។

បទថា **ឯកាគារិកំ** បានដល់ ប្លន់យកទ្រព្យតែផ្ទះមួយ ។

បទថា **បរិបន្ថេ** បានដល់ ចាំស្ទាក់ផ្លូវ ដើម្បីវាយដណ្តើមអ្នកដែលដើរទៅ ដើរមក ។

ដោយបទថា **ករតោ ន ករិយតិ បាបំ** អកិរិយវាទីបុគ្គលទាំងឡាយរមែងសម្តែងថា កាលបុគ្គលសូម្បីធ្វើហើយ ដោយសេចក្តីសម្គាល់ថា យើងធ្វើបាបណាមួយ បាបក៏មិនមែនជាការធ្វើ បាបមិនមាន ប៉ុន្តែថា សត្វទាំងឡាយមានសេចក្តីសម្គាល់យ៉ាងនេះថា យើងធ្វើ ។

បទថា **ខុរបរិយន្តេន** សេចក្តីថា ដោយមុតកាំបិតកោរ ឬដោយចុង (ដែលមុត) ដូចមុតកាំបិតកោរ ។

បទថា **ឯកំ មំសខលំ** បានដល់ គំនរនៃសាច់តែមួយ ។

បទថា **បុញ្ញំ** ជាវេវចនៈនៃបទថា **មំសខលំ** នោះឯង ។

បទថា **តតោនិទានំ** បានដល់ មានការធ្វើឲ្យជាលានសាច់តែមួយជាហេតុ ។

បទថា **ទក្ខិណំ** សេចក្តីថា មនុស្សនៅត្រើយខាងស្តាំ ជាបុគ្គលឃោឃៅ ព្រះមានព្រះភាគទ្រង់សំដៅយកបុគ្គលទាំងនោះ ទើបត្រាស់ពាក្យថា **ហនន្តោ** ជាដើម ។ មនុស្សនៅត្រើយខាងឆ្វេង ជាអ្នកមានសទ្ធាជ្រះថ្លា ជាពុទ្ធមាមកៈ ធម្មមាមកៈ សង្ឃមាមកៈ ព្រះមានព្រះភាគ ទ្រង់សំដៅយកបុគ្គលទាំងនោះ ទើបត្រាស់ពាក្យថា **ទទន្តោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **យជន្តោ** បានដល់ ធ្វើការបូជាធំ ។

បទថា **ទមេន** គឺ ដោយការទូន្មានឥន្ទ្រិយ បានដល់ ដោយឧបោសថកម្ម ។

បទថា **សំយមេន** គឺ ដោយការរក្សាសីល ។

បទថា **សច្ចវជ្ជេន** គឺ ដោយការពោលពាក្យសច្ចៈ ។

បទថា **អាគមោ** ប្រែថា ការមក អធិប្បាយថា ការប្រព្រឹត្តទៅ ។

អកិរិយវាទីបុគ្គល បដិសេធការធ្វើបុណ្យ និងបាបដោយសព្វគ្រប់ ។

ចប់អដ្ឋកថា ករោតោសូត្រទី ៦

# អ ដ្ឋ ក ថា

## ហេតុសូត្រទី ៧

[១៥៦] *បទថា បច្ចយោ ក្នុងបទនេះថា នត្ថិ ហេតុ នត្ថិ បច្ចយោ ជាវេវចនៈរបស់ហេតុនុ៎ះឯង ។*

*អហេតុកវាទីបុគ្គល នាំគ្នាបដិសេធបច្ច័យនៃសេចក្ដីសៅហ្មង នៃសត្តិ-លេសធម៌ទាំងឡាយ មានកាយទុច្ចរិតជាដើម និងបច្ច័យនៃសេចក្ដីបរិសុទ្ធិនៃវោទានធម៌ទាំងឡាយ មានកាយសុចរិតជាដើម ដោយបទទាំងពីរ (នត្ថិ ហេតុ នត្ថិ បច្ចយោ) ។*

*សត្វទាំងឡាយនេះ តាំងនៅក្នុងកម្លាំងរបស់ខ្លួនយ៉ាងណា ហើយទើបសម្រេចដល់ភាពជាទេវតាខ្លះ ជាមារខ្លះ ជាព្រហ្មខ្លះ សាវកពោធិញ្ញាណខ្លះ ព្រះសព្វញ្ញុតញ្ញាណខ្លះ អហេតុកវាទីបុគ្គលបដិសេធកម្លាំងនោះ ដោយបទថា នត្ថិ ពលំ ។*

*បទដទៃទាំងអស់ មានជាដើម គឺ នត្ថិ វីរិយំ ជាវេវចនៈរបស់គ្នានិងគ្នានោះឯង តែបទទាំងនេះចែកទុកផ្សេងគ្នា ក៏ព្រោះបដិសេធពាក្យនិយាយដែលប្រព្រឹត្តទៅយ៉ាងនេះថា ផលនេះគប្បីសម្រេចដោយកម្លាំងរបស់បុរស*

ផលនេះគប្បីសម្រេចដោយសេចក្ដីឧស្សាហ៍របស់បុរស ។

អហេតុកវាទីបុគ្គល សំដៅដល់សត្វទាំងឡាយមិនមានសល់ មាន អូដ្ឋ គោ និងលាជាដើម ដោយបទថា **សព្វេ សត្តា** ។

អហេតុកវាទីបុគ្គល ពោលថា **សព្វេ បាណា** ដោយអំណាចសំដៅយក មានជាដើម គឺ សត្វមានឥន្ទ្រិយតែម្យ៉ាង ។

អហេតុកវាទីបុគ្គល ពោលថា **សព្វេ ភូតា** សំដៅយកសត្វទាំងឡាយដែលកើតហើយក្នុងសំបកពង និងផ្ទៃ (ស្បូន) ។

អហេតុកវាទីបុគ្គល ពោលថា **សព្វេ ជីវា** សំដៅយក ជីវៈទាំងឡាយមានស្រូវសាលី ស្រូវខ្សាយ និងស្រូវជំណើបជាដើម អធិប្បាយថា ក្នុងវត្ថុដែលមានជីវិតទាំងនោះ ជីវៈទាំងនោះដែលបានដឹងថា ជាជីវៈ ព្រោះមានការដុះលូតលាស់ឡើងបាន ។

បទថា **អវសា អពលា អវីរិយា** សេចក្ដីថា វត្ថុដែលមានជីវិតទាំងនោះ មិនមានអំណាច កម្លាំង ឬវីរិយៈនៃខ្លួនឯង ។

ក្នុងបទថា **និយតិសង្គតិភាវបរិណតា** នេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **និយតិ** បានដល់ ភាពជាអ្នកមានជោគល្អ និងជោគអាក្រក់ ។

បទថា **សង្គតិ** បានដល់ ការប្រព្រឹត្តទៅក្នុងអភិជាតិ (កំណើត) នោះៗ បណ្ដាអភិជាតិ ៦ យ៉ាង ។

បទថា **ភាវោ** បានដល់ សភាវៈនុ៎ះឯង ។

វត្ថុដែលមានជីវិតទាំងឡាយ ប្រែប្រួលទៅ គឺ ដល់ភាវៈច្រើនប្រការ តាមសភាពនៃការមានជាតិល្អ និងជាតិអាក្រក់ និងសភាពនៃការប្រព្រឹត្តទៅ (ក្នុងអភិជាតិផ្សេងៗ) ។ ពិតណាស់ អហេតុកវាទីបុគ្គលសម្ដែងថា បុគ្គលណានឹងត្រូវប្រព្រឹត្តទៅយ៉ាងណា បុគ្គលនោះក៏នឹងត្រូវប្រព្រឹត្តទៅយ៉ាងនោះឯង (តែ) បុគ្គលណានឹងមិនប្រព្រឹត្តទៅយ៉ាងណា បុគ្គលនោះក៏នឹងមិនប្រព្រឹត្តទៅយ៉ាងនោះ ដោយពិត ។

ដោយបទថា **ឆស្វេវាភិជាតីសុ** អហេតុកវាទីបុគ្គលសម្ដែងថា វត្ថុដែលមានជីវិតទាំងឡាយ មានជីវិតតាំងនៅ សោយសុខ និងទុក្ខនៅក្នុងអភិ-ជាតិ ៦ ប៉ុណ្ណោះ មិនមានភូមិសម្រាប់សោយសុខ និងទុក្ខដទៃ ។

ចប់អដ្ឋកថា ហេតុសូត្រទី ៧

# អ ដ្ឋ ក ថា

## មហានិទ្ទិសូត្រជាដើម ដល់សូត្រទី ១០

[១៥៨] *បទថា* ***អកដា*** *គឺ (កាយទាំង ៧) មិនមានអ្នកណាសាង ។*

*បទថា* ***អកដវិធា*** *គឺ មិនមានអ្នកណាធ្វើការចាត់ចែង (កសាង) អធិប្បាយថា សូម្បីដែលអ្នកណាៗ ឲ្យធ្វើ ដោយប្រាប់ថា ចូរធ្វើយ៉ាងនេះ ក៏មិនមាន ។*

*បទថា* ***អនិម្មិតា*** *គឺ មិនមានអ្នកណានិម្មិតសូម្បីដោយឫទ្ធិ ។*

*បទថា* ***អនិម្មិតវិធា*** *គឺ ការចាត់ចែង មិនមានអ្នកណានិម្មិត ។ អធិប្បាយថា មិនមែនអ្នកណាៗ គួរនិម្មិតបាន ។ បាឋៈថា* ***អនិម្មិតញ្ញា*** *ដូច្នេះខ្លះ ។*

*បទថា* ***វញ្ឈា*** *គឺ មិនមានផល បានដល់ មិនឲ្យកើតផលអ្វីៗ ដូចសត្វចិញ្ចឹមដែលគ្មានកូន និងដើមត្នោតឈ្មោលជាដើម ។*

*បទថា* ***កូដដ្ឋា*** *សេចក្តីថា តាំងនៅដូចកំពូលភ្នំ (ព្រោះហេតុនោះ) ទើបឈ្មោះថា* ***កូដដ្ឋា*** *។*

*បទថា* ***ឯសិកដ្ឋាយិដ្ឋិតា*** *តាំងនៅ តាំងនៅដូចជាសសរគោល ព្រោះហេតុនោះទើបឈ្មោះថា* ***ឯសិកដ្ឋាយិដ្ឋិតា*** *អធិប្បាយថា សសរគោលដែល*

កប់ល្អហើយ តាំងមាំមិនញាប់ញ័រ យ៉ាងណា កាយក៏តាំងនៅដូច្នោះ ។

បទថា **ន ឥញ្ជន្តិ** សេចក្តីថា មិនញាប់ញ័រ តាំងនៅមាំដូចសសរគោល ដូច្នោះ ។

បទថា **ន វិបរិណាមន្តិ** សេចក្តីថា មិនលះបង់ប្រក្រតី ។

បទថា **ន អញ្ញមញ្ញំ ព្យាពេន្តិ** សេចក្តីថា មិនបៀតបៀនគ្នានិងគ្នា ។

បទថា **នាលំ** ប្រែថា មិនអាច ។

ក្នុងបទថា **បឋវីកាយោ** ជាដើម មានអធិប្បាយថា បឋវីនុ៎ះឯងឈ្មោះថា បឋវីកាយៈ (គំនរដី) ឬបឋវីសមូហៈ (ប្រជុំដី) ។

បទថា **សត្តន្នំ ត្វេវ កាយានំ** មានសេចក្តីថា សស្ត្រាដែលចាក់ចូលទៅក្នុងគំនរសណ្តែកបាយជាដើម រមែងចូលទៅក្នុងចន្លោះសណ្តែកបាយជាដើម យ៉ាងណា សស្ត្រាក៏ជ្រែកចូលទៅក្នុងចន្លោះ គឺ ផ្លូវ បានដល់ ផ្លូវដែលជាចន្លោះរបស់កាយទាំង ៧ ដូច្នោះ ។

ក្នុងការសម្លាប់នោះ ពួកមិច្ឆាទិដ្ឋិសម្តែងថា នឹងមានត្រឹមតែការសម្គាល់តែម្យ៉ាងប៉ុណ្ណោះថា យើងផ្តាច់ជីវិតអ្នកនេះ (សម្លាប់សត្វ) ។

មិច្ឆាទិដ្ឋិកបុគ្គល (អ្នកនិយមក្នុងលទ្ធិនេះ) នាំគ្នាសម្តែងការជឿបែបគ្មានប្រយោជន៍ (ដែលបានមក) ដោយហេតុត្រឹមតែការត្រិះរិះតែម្យ៉ាង (ដោយ

ប្រើគោលតក្កវិទ្យាតែម្យ៉ាង) ថា កំណើតធំ គឺ កំណើតដែលសំខាន់ មាន ១.៤០០.០០០ រួមជាមួយកំណើតដទៃទៀត ៦.៦០០ និងកម្ម ៥០០ ទៀត ដោយបទថា **យោនិបមុខសតសហស្សានិ** ។

សូម្បីក្នុងបទថា **បញ្ច ច កម្មានិ តីណិ ច កម្មានិ** (កម្ម ៥ និងកម្ម ៣) ជាដើម ក៏មានន័យដូចគ្នានេះឯង ។

ចំណែកអាចារ្យពួកខ្លះពោលថា មិច្ឆាទិដ្ឋិកបុគ្គលទាំងឡាយពោលដល់កម្ម ៥ ដោយអំណាចឥន្ទ្រិយ ៥ , ពោលដល់កម្ម ៣ ដោយអំណាចកាយកម្មជាដើម ។

ចំណែកក្នុងបទថា **កម្មេ ច អឌ្ឍកម្មេ ច** (កម្ម និងកន្លះកម្ម) នេះ មានអធិប្បាយថា កាយកម្ម និងវចីកម្មរបស់ម្ចាស់លទ្ធិនោះ បានឈ្មោះថា **ជាកម្ម** មនោកម្ម បានឈ្មោះថា **ជាកម្មពាក់កណ្តាល** ។

មិច្ឆាទិដ្ឋិកបុគ្គលពោលថា បដិបទា មាន ៦២ ដោយបទថា **ទ្វដ្ឋិ-ប្បដិបទា** ។

បទថា **ទ្វដ្ឋន្តរកប្បា** សេចក្តីថា ក្នុងកប្បធំមួយ មានកប្បឈ្មោះថា អន្តរកប្ប (កប្បតូច) ៦៤ កប្ប ។

ប៉ុន្តែថា ម្ចាស់លទ្ធិនេះ មិនដឹងកប្បដទៃ ២ ទៀត (សំវដ្តដ្ឋាយីកប្ប ១

វិវដ្ដដ្ឋាយីកប្ប ១) ទើបពោល យ៉ាងនេះ ។

មិច្ឆាទិដ្ឋិកបុគ្គលពោលដល់ អភិជាតិ (កំណើត) ៦ ទាំងនេះ គឺ កណ្ហាភិជាតិ ១ នីលាភិជាតិ ១ លោហិតាភិជាតិ ១ ហលិទ្ទាភិជាតិ ១ សុក្កាភិជាតិ ១ បរមសុក្កាភិជាតិ ១ ដោយបទថា **ឆឡាភិជាតិយោ** ។

មិច្ឆាទិដ្ឋិកបុគ្គលពោលថា បណ្ដាកំណើតទាំង ៦ នោះ ឱរព្ភិកកំណើត (ការកើតជានាយព្រានកែះ) សូករិកកំណើត (ការកើតជានាយព្រានជ្រូក) សាកុណិកកំណើត (ការកើតជានាយព្រានបក្សី) មាគវិកកំណើត (ការកើតជានាយព្រាណ៍ម្រឹគ) លុទ្ទកំណើត (ការកើតជានាយព្រាន) មច្ឆឃាតក-កំណើត (ការកើតជាព្រានប្រមង់) ចោរកំណើត (ការកើតជាចោរ) ចោរឃា-ដកំណើត (ការកើតជាពេជ្រឃាតសម្លាប់ចោរ) ពន្ធនាគារិកកំណើត (ការកើតមេគុក) ឬថា ការងារដែលតិចតួចដទៃយ៉ាងណាមួយ នេះឈ្មោះថា **កណ្ហាភិជាតិ** (កំណើតខ្មៅ) ។

កំណើតភិក្ខុ មិច្ឆាទិដ្ឋិកបុគ្គលពោលថា **នីលាភិជាតិ** (កំណើតខៀវ) បានឮថា ភិក្ខុទាំងនោះដាក់បន្លាទៅក្នុងបច្ច័យ ៤ ហើយទើបឆាន់ (អាហារ) និងភិក្ខុទាំងឡាយក៏ចិញ្ចឹមជីវិតដោយអាស្រ័យបន្លា ក៏បាលីដូចពោលមកនេះ ជាបាលីរបស់ភិក្ខុនោះឯង ។

ម្យ៉ាងទៀត គេពោលគ្នាថា អ្នកបួសទាំងឡាយ ដូចជានៅក្នុងព្រៃបន្ទា ទើបមានឈ្មោះយ៉ាងនេះ (**កណ្ហកវុត្តិកា**) ។

គេពោលថា ពួកនិគ្រន្ថដែល ប្រើសំពត់ផ្ទាំងតែមួយ ឈ្មោះថា **លោហិតាភិជាតិ** (កំណើតក្រហម) ដែលបានដឹងថា និគ្រន្ថទាំងនេះបរិសុទ្ធិជាង ២ ពួកដំបូង ។

គេពោលថា សាវករបស់អចេលកៈដែលជាគ្រហស្ថ ស្លៀកសដណ្តប់ស ឈ្មោះថា **ហលិទ្ទាភិជាតិ** (កំណើតលឿង) និគ្រន្ថទាំងឡាយ ធ្វើពួកសាវកដែលជាគ្រហស្ថ ថ្វាយបច្ច័យរបស់ខ្លួន ឲ្យមានភាពសំខាន់ជាងពួកនិគ្រន្ថផងគ្នា ដោយអាការយ៉ាងនេះ ។

គេពោលថា ពួកអាជីវកប្រុស ពួកអាជីវកស្រី នេះឈ្មោះថា **សុក្កាភិជាតិ** ដែលគេដឹងថា អាជីវកទាំងស្រី និងប្រុសទាំងនោះ បរិសុទ្ធិជាង ៤ ពួកដំបូង ។

គេពោលថា ម្ចាស់លទ្ធិឈ្មោះ នន្ទៈ វច្ឆៈ សង្កិច្ចៈ និងមក្ខលិគោសាល ឈ្មោះថា **បរមសុក្កាភិជាតិ** ។ ដែលគេដឹងថា ម្ចាស់លទ្ធិទាំងនោះ បរិសុទ្ធិជាងពួកដទៃទាំងអស់ ។

មិច្ឆាទិដ្ឋិកបុគ្គលពោលថា **ភូមិ** (លំដាប់នៃការចម្រើនជំពាត់) របស់

បុគ្គលមាន ៨ ភូមិទាំងនេះ គឺ មន្ទភូមិ ១ ខិឌ្ឌាភូមិ ១ វីមំសកភូមិ ១ ឧជុគតភូមិ ១ សេក្ខភូមិ ១ សមណភូមិ ១ ជានទភូមិ ១ បន្នភូមិ ១ ដោយបទថា **អដ្ឋ បុរិសភូមិយោ** ។

បណ្តាភូមិទាំង ៨ នោះ ប្រសូតិមកក្នុង (វេលា) ៧ ថ្ងៃ ផ្តើមតាំងពីថ្ងៃកើត សត្វទាំងឡាយរាប់ថានៅទន់ខ្ចី ល្ងង់ខ្លៅ ព្រោះចេញមកពីទីចង្អៀត គេថា នេះឈ្មោះថា **មន្ទភូមិ** ។

ចំណែកសត្វពួកណាមកពីទុគ្គតិ សត្វទាំងនោះ ស្រែកយំរឿយៗ និងស្រែកយំខ្លាំងៗ , (ចំណែក) សត្វពួកណាមកពីសុគតិ សត្វទាំងនោះនឹកដល់សុគតិនោះហើយ ក៏សើចសប្បាយ នេះឈ្មោះថា **ខិឌ្ឌាភូមិ** ។

ការចាប់ដៃ ឬជើងរបស់មាតាបិតា (ឬ) ចាប់គ្រែ ឬតាំង ហើយដាក់ជើងចុះជាន់ផែនដី ឈ្មោះថា **វីមំសកភូមិ** ។

វេលាដែលអាចដើរបាន ឈ្មោះថា **ឧជុគតភូមិ** ។

រយៈពេលដែលសិក្សាសិល្បៈ ឈ្មោះថា **សេក្ខភូមិ** ។

វេលាដែលចេញចាកផ្ទះបួស ឈ្មោះថា **សមណភូមិ** ។

វេលាដែលចេះដឹង ព្រោះសេព (សិក្សាមកពី) អាចារ្យ ឈ្មោះថា **ជានទភូមិ** ។

គេពោលដល់សមណៈដែលមិនខ្ចាតយ៉ាងនេះថា ក៏កិក្ខុជាអ្នកក្ខាត់ (ចាកប្រយោជន៍) ហើយ (ព្រោះ) ព្រះជិនស្រីមិនត្រាស់អ្វីទុក នេះឈ្មោះថា **បន្នភូមិ** ។

បទថា **ឯកូនបញ្ញាស អាជីវកសតេ** បានដល់ វិធីដំណើរជីវិត ៤.៩០០ ។

បទថា **បរិព្វាជកសតេ** បានដល់ ការបួសជាបរិព្វាជក ១០០ ។

បទថា **នាគវាសសតេ** បានដល់ នាគមណ្ឌល ១០០ ។

បទថា **វីសេ ឥន្ទ្រិយសតេ** បានដល់ ឥន្ទ្រិយ ២.០០០ ។

បទថា **តឹសេ និរយសតេ** បានដល់ នរក ៣.០០០ ។

មិច្ឆាទិដ្ឋិកបុគ្គលពោលសំដៅដល់ខ្នងដៃ និងខ្នងជើងជាដើម ដែលជាទីកោយធូលីចុះ ដោយបទថា **រជោធាតុយោ** ។

ពោលសំដៅដល់ អូដ្ឋ គោ លា ពពែ សត្វ ចិញ្ចឹម ម្រឹគ និងក្របី ដោយបទថា **សត្តសញ្ញិគព្ភា** ។

ពោលសំដៅដល់ ស្រូវសាលី ស្រូវដំណើប ស្រូវខ្សាយ ស្រងែ ថ្ពៅ ស្គួយ និងស្មៅគែលលក ដោយបទថា **អសញ្ញិគព្ភា** ។

ពោលសំដៅដល់ ដើមអំពៅ ដើមឫស្សី និងដើមអំពៅជាដើម ដែល

មានដើម (ថ្មី) ដុះឡើងត្រង់ថ្ងាំង ដោយបទថា **និគ្គណ្ឋិគព្ភា** ។

បទថា **សត្ត ទិព្វា** បានដល់ ទេពចំនួនច្រើន ក៏មិច្ឆាទិដ្ឋិកបុគ្គលនោះហៅ (ទេពទាំងនោះ) ថាសត្វ ។ សូម្បីមនុស្សក៏មានចំនួនច្រើន គេក៏ហៅ (មនុស្សទាំងនោះ) ថាសត្វ ។

បទថា **សត្ត បិសាចា** បានដល់ បីសាចចំនួនច្រើន មិច្ឆាទិដ្ឋិកបុគ្គលក៏ហៅ (បីសាចចំនួនច្រើនទាំងនោះ) ថាសត្វ ។

បទថា **សរា** បានដល់ ស្រះធំ គេពោលសំដៅដល់ ស្រះកណ្ណមុណ្ឌៈ ស្រះរថការៈ ស្រះអនោតាតៈ ស្រះសីហបបាតៈ ស្រះមណ្ឌាកិនី ស្រះមុចលិន្ទ និងស្រះកុណាលៈ ។

បទថា **បវុជា** បានដល់ អន្លង់ ។

បទថា **បបាតា** បានដល់ ជ្រោះធំ ។

បទថា **បបាតសតានិ** បានដល់ ជ្រោះតូច ៧០០ ។

បទថា **សុបិនា** បានដល់ សុបិនធំ ៧ ។

បទថា **សុបិនសតានិ** បានដល់ សុបិនតូច ៧០០ ។

បទថា **មហាកប្បិនោ** បានដល់ មហាកប្បទាំងឡាយ

ក្នុងប្រការនេះ ម្ចាស់លទ្ធិនោះ មានការឃើញដូច្នេះថា កាលបុគ្គល

យកចុងស្បូវជ្រលក់ទឹកពីស្រះធំ ១ ដោយ ១០០ ឆ្នាំ តែទឹក ១ តំណក់ ហើយធ្វើស្រះនោះឲ្យរីងអស់ ៧ ដង (យ៉ាងនេះ) ចាត់ជាមហាកប្ប ១ ។ ពាល និងបណ្ឌិត បណ្ដាយមហាកប្បបែបនេះ អស់ទៅបាន ៨.៤០០.០០០ មហាកប្ប ក៏នឹងធ្វើទីបំផុតទុក្ខបាន ។

គេជឿថា ក្នុងរយៈវេលាចន្លោះនោះ សូម្បីបណ្ឌិតក៏មិនអាចនឹងបរិសុទ្ធិបាន ទាំងជនពាលក៏មិនកន្លងហួសអំពីនោះទៅបាន ។

បទថា **សីលេន វា** បានដល់ ដោយសីលរបស់អចេលកៈ ឬដោយសីលយ៉ាងដទៃប្រភេទណាមួយ សូម្បីដោយវត្តក៏ដូច្នោះដូចគ្នា ។

បទថា **តបេន** សេចក្ដីថា អ្នកណាគិតថា យើងជាបណ្ឌិត ហើយបរិសុទ្ធិក្នុងរយៈវេលាចន្លោះ (មហាកប្បទាំងនោះ) អ្នកនោះឈ្មោះថា ធ្វើកម្មដែលនៅមិនទាន់ទុំជោរ ឲ្យទុំជោរ ដោយការបំពេញតបៈ ។ អ្នកណាគិតថា គេជាពាលដូច្នេះហើយ កន្លងហួសវេលាកំណត់ ដូចពោលហើយ អ្នកនោះឈ្មោះថា បានប្រសព្វកម្មដែលនៅមិនទាន់ទុំជោរ ហើយធ្វើឲ្យដល់នូវទីបំផុតទៅបាន ។

បទថា **ហេវំ នត្ថិ** គឺ **ឯវំ នត្ថិ** ។ ក៏កម្មទាំងពីរយ៉ាងនោះ ម្ចាស់លទ្ធិសម្ដែងថា នរណាៗ មិនអាចនឹងធ្វើបាន ។

បទថា **ទោណមិតេ** ប្រែថា ដូចជាវាល់ដោយនាឡិ ។

បទថា **សុខទុក្ខេ** គឺ **សុខទុក្ខំ** (ប្រែថា សុខ និងទុក្ខ) ។

បទថា **បរិយន្តកតេ** គឺ (សង្សារវដ្ត) ត្រូវធ្វើឲ្យមានទីបំផុតបានតាមវេលាមានកំណត់ដូចពោលហើយ ។

បទថា **នត្ថិ ហាយនវឌ្ឍនេ** គឺ មិនមានការវិនាស និងចម្រើន អធិប្បាយថា សង្សារវដ្តរបស់បណ្ឌិតក៏មិនវិនាស (ដល់ទីបំផុត) របស់ជនពាលក៏មិនចម្រើន (លូតលាស់) ។

បទថា **ឧក្កំសាវកំសេ** នេះ ជាវេវចនៈរបស់សេចក្តីវិនាស និងសេចក្តីចម្រើនដូចគ្នា ។

ឥឡូវនេះ កាលនឹងឲ្យអត្ថនោះសម្រេចដោយឧបមា ព្រះមានព្រះភាគទើបត្រាស់ពាក្យថា **សេយ្យថាបិ នាម** ជាដើម ។

បណ្តាបទទាំងនោះ បទថា **សុត្តគុឡេ** បានដល់ ដុំអំបោះដែលខារទុកកំពុងរលាចេញទៅនុ៎ះឯង ។

ដោយបទថា **បលេតិ** ម្ចាស់លទ្ធិសម្តែងថា ដុំអំបោះដែលដាក់ (ត្រង់កន្លែងមួយ) ទុកលើភ្នំ ឬលើចុងឈើ ហើយគេវែងទៅ នឹងរលាទៅតាមប្រវែងរបស់អំបោះ កាលអំបោះអស់ហើយ ក៏នឹងឈប់ក្នុងទីនោះឯង មិន

*វេលា.តទៅទៀត យ៉ាងណា ពាល និងបណ្ឌិតក៏ដូច្នោះដែរ កាលបើកែខៃទៅ ក៏នឹងដល់ទីបំផុតសេចក្ដីសុខសេចក្ដីទុក្ខបាន តាមអំណាចកាលវេលា គឺ នឹងកន្លងផុតសុខទុក្ខទៅបាន តាមកាលវេលាដូចពោលហើយ ។*

ចប់អដ្ឋកថា សូត្រទី ៨ ដល់សូត្រទី ១០

# អ ដ្ឋ ក ថា

## អន្តវាសូត្រទី ១១ ជាដើម ដល់សូត្រទី ១៨

[១៦៣] បទថា *អន្តវា លោកោ* សេចក្តីថា ទិដ្ឋិដែលកើតឡើងដោយការប្រកាន់នោះ ឬដោយការត្រិះរិះថា លោក គឺ និមិត្តដែលផ្សាយទៅបានផ្នែកមួយ (មានទីបំផុត) ។

[១៦៤] បទថា *អនន្តវា* សេចក្តីថា ទិដ្ឋិដែលកើតឡើងដោយការប្រកាន់នោះ ឬដោយការត្រិះរិះថា លោក គឺ និមិត្តដែលកំណត់ទំហំមិនបាន ផ្សាយទៅគ្រប់ផ្នែក (មិនមានទីបំផុត) ។

[១៦៥] បទថា *តំ ជីវំ តំ សរីរំ* បានដល់ ទិដ្ឋិដែលកើតឡើងថា ជីវៈ និងសរីរៈ តែមួយ៉ាងដូចគ្នា ។

បទដ៏សេសគ្រប់កន្លែង មានសេចក្តីងាយនោះឯង ។

មួយ៉ាងទៀត វេយ្យាករណ៍ទាំងនេះ មាន ១៨ យ៉ាង ដោយអំណាចសោតាបត្តិមគ្គមុន នេះជាការដល់លើកទី ១ ។

ចប់អដ្ឋកថា សោតាបត្តិវគ្គទី ១

# ចប់សោតាបត្តិវគ្គ

## រួមក្នុងវគ្គនេះមាន ០៧ អដ្ឋកថា


១-អដ្ឋកថា វាតសូត្រ ២-អដ្ឋកថា ឯតំមម ដល់នោច...សូត្រ

៥-អដ្ឋកថា នត្ថិទិន្នសូត្រ ៦-អដ្ឋកថា ករោតោសូត្រ

៧-អដ្ឋកថា ហេតុសូត្រ ១០-អដ្ឋកថា មហាទិដ្ឋិ ដល់អស្ស...សូត្រ

១១-អដ្ឋកថា អន្តវាសូត្រ ដល់សូត្រទី១៨

# អ ដ្ឋ ក ថា

## ទុតិយគមនាទិវគ្គ[1]

*ការដល់លើកទី ២ ព្រះមានព្រះភាគត្រាស់ទុក ដោយអំណាចទុក្ខសូម្បីក្នុងប្រការនេះ វេយ្យាករណ៍ក៏មាន ១៨ តអំពីវេយ្យាករណ៍ ១៨ នោះទៅ ក៏មានវេយ្យាករណ៍ ៨ មានជាដើមថា* **ខន្ធមានរូប** *ដូច្នេះ ។ ការដល់នោះ រួមជាមួយវេយ្យាករណ៍ទាំងនោះ ព្រះមានព្រះភាគត្រាស់ទុកក្នុងវេ-យ្យាករណ៍ទី ២ ដូច្នេះឯង ។*

[១៧៦] *បណ្ដាបទទាំងនោះ បទថា រូបី បានដល់ អារម្មណ៍នុ៎ះឯង គឺ ទិដ្ឋិដែលប្រកាន់ (អារម្មណ៍) ថា ជាអត្តា ។*

ចប់អដ្ឋកថា រូបីអត្តសូត្រទី ១៩

---

*១-ព្រះសូត្រ ជាទុតិយបេយ្យាល ។*

# អ ដ្ឋ ក ថា

## អរូបីអត្ថសូត្រទី ២០

[១៧៨] *បទថា អរូបី បានដល់ ឈាន គឺ ទិដ្ឋិដែលប្រកាន់ឈានថាជាខ្លួន ។*

ចប់អដ្ឋកថា អរូបីអត្ថសូត្រទី ២០

# អ ដ្ឋ ក ថា

## រូបីចអរូបីអត្តសូត្រទី ២១

[១៧៩] *បទថា រូបី ច អរូបី ច បានដល់ អារម្មណ៍ និងឈាន គឺ ទិដ្ឋិដែលប្រកាន់ (អារម្មណ៍ និងឈាន) ថា ជាខ្លួន ។*

ចប់អដ្ឋកថា រូបីចអរូបីអត្តសូត្រទី ២១

# អ ដ្ឋ ក ថា

## នេវរូបីនារូបីអត្តសូត្រទី ២២

[១៨០] *បទថា នេវរូបីនារូបី បានដល់ ទិដ្ឋិដែលប្រកាន់ដោយហេតុត្រឹមតែការត្រិះរិះ ។*

ចប់អដ្ឋកថា នេវរូបីនារូបីអត្តសូត្រទី ២២

# អ ដ្ឋ ក ថា

## ឯកន្តសុខីសូត្រទី ២៣

[១៨១] បទថា ឯកន្តសុខី បានដល់ ទិដ្ឋិដែលកើតឡើងដល់បុគ្គលអ្នកបានឈានហើយត្រិះរិះ (ជាតក្កវិទ្យា) និងបុគ្គលរឭកជាតិបាន ។

អធិប្បាយថា ទិដ្ឋិនេះ (អត្តាមានសុខដោយចំណែកតែមួយ) រមែងកើតឡើងសូម្បីដល់បុគ្គលដែលបានឈាន ធ្វើទុកក្នុងចិត្តដល់អត្តភាព ដែលមានសុខដោយចំណែកមួយក្នុងអតីត ។

ចំណែកបុគ្គលដែលត្រិះរិះ ទិដ្ឋិរមែងកើតឡើង (យ៉ាងនេះ) ថា ក្នុងបច្ចុប្បន្ន យើងមានសុខដោយចំណែកមួយ យ៉ាងណា សូម្បីក្នុងអនាគត យើងក៏ជាអ្នកមានសុខដោយចំណែកមួយ ដូច្នោះ ។

ទិដ្ឋិនេះ រមែងកើតឡើង សូម្បីដល់បុគ្គលដែលរឭកជាតិបាន គឺ រឭកដល់ភាវៈដែលជាសុខបាន ៧-៨ ភព ។

ចប់អដ្ឋកថា ឯកន្តសុខីសូត្រទី ២៣

# អ ដ្ឋ ក ថា

## ឯកន្តទុក្ខីសូត្រទី ២៤

[១៨២] *សូម្បីក្នុងបទថា ឯកន្តទុក្ខី ជាដើម ក៏មានន័យនេះដូចគ្នា ។*

ចប់អដ្ឋកថា ឯកន្តទុក្ខីសូត្រទី ២៤

## ចប់ទុតិយបេយ្យាល
## រួមមាន ០៦ អដ្ឋកថា

១៩-អដ្ឋកថា ទុតិយគមនាទិសូត្រ ២០-អដ្ឋកថា អរូបីនោសូត្រ

២១-អដ្ឋកថា រូបីចអរូបីចអត្តសូត្រ ២២-អដ្ឋកថា នេវរូបីនារូបីអត្តសូត្រ

២៣-អដ្ឋកថា ឯកន្តសុខីសូត្រ ២៤-អដ្ឋកថា ឯកន្តទុក្ខីសូត្រ

-៦៧- ធិដ្ឋិសំយុត្ត សោតាបត្តិវគ្គ អដ្ឋកថា តតិយបេយ្យាល

# អ ដ្ឋ ក ថា

## តតិយបេយ្យាល

[១៨៧] *បេយ្យាលទី ៣ ព្រះមានព្រះភាគត្រាស់ទុកដោយសូត្រទាំងនោះឯង (រួម) ២៦ សូត្រ ដោយអំណាច អនិច្ចំ ទុក្ខំ ។*

ចប់អដ្ឋកថា តតិយបេយ្យាលទី ៣

## ចប់តតិយបេយ្យាល

**រួមមាន ០១ អដ្ឋកថា**

១-២៦- អដ្ឋកថា តតិយបេយ្យាល

# អ ដ្ឋ ក ថា

## ចតុត្ថបេយ្យាល

*[១៨៨-១៩៥] ចំណែកបេយ្យាលទី ៤ ត្រាស់ទុកដោយអំណាច*

*បរិវដ្ដៈ ៣ នោះឯង ។*

ចប់អដ្ឋកថា ចតុត្ថបេយ្យាល

## ចប់ចតុត្ថបេយ្យាល

**រួមមាន ០១ អដ្ឋកថា**

១-២៦- អដ្ឋកថា ចតុត្ថបេយ្យាល

## ចប់អដ្ឋកថា ទិដ្ឋិសំយុត្ត

# ឱក្កន្តសំយុត្ត

## អ ដ្ឋ ក ថា

### ចក្ខុសុត្តាទិសូត្រទី ១-១០

[១៩៦] *គប្បីជ្រាបវិនិច្ឆ័យក្នុងឱក្កន្តសំយុត្តដូចតទៅនេះ ៖*

*បទថា* ***អធិមុច្ចតិ*** *បានដល់ រមែងបាន* ***សទ្ធាធិមោក្ខ*** *។*

*បទថា* ***ឱក្កន្តោ សម្មត្តនិយាមំ*** *បានដល់ ចូលទៅកាន់អរិយមគ្គ ។*

*ដោយបទថា* ***អភព្វោ តាវ កាលំ កាតុំ*** *នេះ ព្រះមានព្រះភាគទ្រង់សម្តែងដល់សេចក្តីមិនមានអន្តរាយ (គ្រឿងរារាំង) ដល់ផល កាលមគ្គកើតឡើងហើយ ។ ព្រោះថា កាលមគ្គកើតឡើងហើយ ដែលឈ្មោះថាការធ្វើអន្តរាយ (គ្រឿងរារាំង) ដល់ផលមិនមាន ដោយហេតុនោះឯង ព្រះមានព្រះភាគទើបត្រាស់ថា ក៏បុគ្គលនេះគប្បីជាអ្នកបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល សូម្បីវេលាដែលកប្បនឹងត្រូវភ្លើងឆេះ ក៏គង់មាន (ប៉ុន្តែថា) កប្បនេះនឹងមិនគប្បីត្រូវភ្លើងឆេះ ដរាបណាដែលបុគ្គលនេះ មិន*

ទាន់ធ្វើឲ្យច្បាស់នូវសោតាបត្តិផល បុគ្គលនេះ ទើបត្រូវហៅថា អ្នកតាំងនៅអស់នៃកប្ប ។

បទថា មត្តសោ និជ្ឈានំ ខមន្តិ សេចក្តីថា គួរដល់ការពិចារណាមើលជាប្រមាណ ។ បទដ៏សេសក្នុងទីគ្រប់កន្លែង មានន័យងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា ឱក្កន្តសំយុត្ត ទី ៤

## ចប់ឱក្កន្តសំយុត្ត

### ក្នុងសំយុត្តនេះមាន ០១ អដ្ឋកថា

១-អដ្ឋកថា ចក្ខុសុត្តាទិសូត្រទី ១-១០

# ឧប្បាទសំយុត្ត

## អ ដ្ឋ ក ថា

## សូត្រទី ១-១០

[២០៦-២២៥] *ពាក្យទាំងអស់ក្នុងឧប្បាទសំយុត្ត ជាក់ច្បាស់ហើយនោះឯង ។*

ចប់អដ្ឋកថា ឧប្បាទសំយុត្តទី ៥

**ចប់ឧប្បាទសំយុត្ត**
**ក្នុងសំយុត្តនេះមិនមានអដ្ឋកថាកែនេ**

# កិលេសសំយុត្ត

## អ ដ្ឋ ក ថា

### សុត្រទី ១-១០

*គប្បីជ្រាបវិនិច្ឆ័យក្នុង **កិលេសសំយុត្ត** ដូចតទៅនេះ ៖*

[២២៦-២៣៥] *បទថា **ចិត្តស្សេសោ ឧបក្កិលេសោ** សេចក្តីថា (ជាឧបក្កិលេស) របស់ចិត្តដូចណា ?*

*(ជាឧបក្កិលេស) របស់ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។*

*សួរថា (ឆន្ទរាគៈជាឧបក្កិលេស) របស់ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ រាប់ថាត្រឹមត្រូវ (តែ) (ជាឧបក្កិលេស) របស់លោកុត្តរចិត្តដូចម្តេច ?*

*ឆ្លើយថា បានព្រោះហាមការកើតឡើង (នៃលោកុត្តរចិត្ត) អធិប្បាយថា ឆន្ទរាគៈនោះ គប្បីជ្រាបថាជាឧបក្កិលេស ព្រោះមិនឲ្យលោកុត្តរចិត្តនោះកើតឡើង ។*

*បទថា **នេក្ខម្មនិន្នំ** បានដល់ (ចិត្ត) ដែលបង្អោនទៅក្នុងលោកុត្តរធម៌*

៩ ។

បទថា ចិត្តំ បានដល់ ចិត្តដែលចម្រើនសមថៈ និងចិត្តដែលចម្រើនវិបស្សនា ។

បទថា **អភិញ្ញា សច្ឆិករណីយេសុ ធម្មេសុ** សេចក្តីថា ឬកាលបុគ្គលចាប់ប្រកាន់ធម៌ណាមួយ ក្នុងបណ្តាធម៌ គឺ អភិញ្ញា ប្រការទី ៦ ដែលគប្បីដឹងហើយ ធ្វើឲ្យច្បាស់ដោយបច្ចវេក្ខណញ្ញាណ ក៏គប្បីប្រកាន់ថា **នេក្ខម្មៈ** ក៏គឺព្រះនិព្វានទុំះឯង ។

បទដ៏សេសក្នុងសូត្រទាំងអស់ មានអត្ថងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា កិលេសសំយុត្ត

## **ចប់កិលេសសំយុត្ត**

**ក្នុងសំយុត្តនេះមាន ០១ អដ្ឋកថា**

១-អដ្ឋកថា កិលេសសំយុត្ត

# សារីបុត្តសំយុត្ត

## អ ដ្ឋ ក ថា

### សុត្រទី ១-៩

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១ នៃសារីបុត្តសំយុត្ត ដូចតទៅនេះ ៖*

[២៣៦-២៤៤] *បទថា ន ឯវំ ហោតិ សេចក្តីថា ព្រោះលោកលះអហង្ការ (ការសម្គាល់ថាយើង) និងមមង្ការ (ការសម្គាល់ថារបស់យើង) បានហើយ ទើបមិនមានការគិតយ៉ាងនេះ ។*

*សូម្បីក្នុងសូត្រទី ២ ជាដើម (ដរាបដល់សូត្រទី ៩) ក៏មានន័យដូចគ្នានោះឯង ។*

ចប់អដ្ឋកថា សុត្រទី ១-៩

# អ ដ្ឋ ក ថា

## សូចិមុខីសូត្រទី ១០

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១០ ដូចតទៅនេះ ៖*

*[២៨៥] បទថា* ***សូចិមុខី*** *គឺ នាងបរិព្វាជិកាដែលមានឈ្មោះយ៉ាងនេះ ។*

*បទថា* ***ឧបសង្កមិ*** *សេចក្តីថា នាងបរិព្វាជិកានោះ ឃើញព្រះថេរៈមានរូបស្អាត គួរពិតពិលរមិលមើល មានពណ៌សម្បុរស្អាតល្អដូចមាស ក៏មានចិត្តជ្រះថ្លាចំពោះលោក ទើបចូលទៅរកដោយគិតថា យើងនឹងធ្វើការរីករាយជាមួយព្រះថេរៈនេះ គ្រានោះ កាលព្រះថេរៈបដិសេធពាក្យនិយាយនោះ នាងទើបគិតថា ឥឡូវនេះ យើងនឹងលើកវាទៈជាមួយព្រះថេរៈនោះ ទើបពោលថា សមណៈ បើដូច្នោះ លោកងើយមុខធាន់ឬ ?*

*បទថា* ***ទិសាមុខោ*** *បានដល់ បែរមុខកាន់ទិសទាំង ៤ ។ អធិប្បាយថា សម្លឹងមើលទាំង ៤ ទិស (ទិសណាមួយ) ។*

*បទថា* ***វិទិសាមុខោ*** *បានដល់ សម្លឹងមើលទិសឈៀងទាំង ៤ ទិស ។*

*បទថា* ***វត្ថុវិជ្ជាតិរច្ឆានវិជ្ជាយ*** *បានដល់ តិរច្ឆានវិជ្ជា ពោលគឺ វិជ្ជា*

មើលទាយផ្ទៃដី ។ ឧបាយជាគ្រឿងដឹងដល់ហេតុដែលធ្វើឲ្យផ្ទៃដីទាំងឡាយមានដីចំការដាំឃ្មោក ត្រឡាច និងដំឡូងជាដើម សម្បូរណ៍ដោយភោគផល ឈ្មោះថា **វិជ្ជាមើលផ្ទៃដី** ។

បទថា **មិច្ឆាជីវេន ជីវិកំ កប្បេន្តិ** សេចក្តីថា ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ពោលគឺ តិរច្ឆានវិជ្ជា បានដល់ វិជ្ជាមើលដីទីនោះៗ ឯង ។

អធិប្បាយថា បរិភោគបច្ច័យដែលពួកជនអ្នកជ្រះថ្លា ព្រោះសេចក្តីសម្បូរណ៍ដោយភោគផលនៃផ្ទៃដីទាំងនោះឯង ។

បទថា **អធោមុខា** សេចក្តីថា ឈ្មោះថា ឱនមុខបរិភោគ ដោយអំណាចមើលផ្ទៃដីហើយបរិភោគ ។

មយ៉ាងទៀត ក្នុងបទទាំងនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **នក្ខត្តវិជ្ជា** បានដល់ វិជ្ជាដែលជាហេតុឲ្យដឹងយ៉ាងនេះថា ថ្ងៃនេះ ឫក្សនេះ គួរទៅដោយឫក្សនេះ មិនគួរទៅដោយឫក្សនេះ គួរធ្វើវត្ថុនេះ ដោយឫក្សនេះ ។

បទថា **ទូតេយ្យំ** បានដល់ ការងាររបស់ទូត គឺ ការទទួលយកសាសន៍របស់បុគ្គលនោះៗ ទៅក្នុងទីនោះៗ ។

បទថា **បហិណគមនំ** បានដល់ ការចូលទៅកាន់ត្រកូលមួយ ដោយ

សាសន៍របស់ត្រកូលមួយទៀត ក្នុងស្រុកជាមួយគ្នានុ៎ះឯង ។

បទថា **អង្គវិជ្ជា** បានដល់ វិជ្ជាជាហេតុឲ្យដឹងអង្គសម្បត្តិ (លក្ខណៈអវយវៈដែលល្អ) តាមឥត្ថីលក្ខណៈ និងបុរិសលក្ខណៈ ហើយជ្រាបយ៉ាងនេះថា បុគ្គលនឹងបានវត្ថុនេះ ដោយអង្គសម្បត្តិយ៉ាងនោះ ។

បទថា **វិទិសាមុខា** សេចក្តីថា ព្រោះថា វិជ្ជាមើលអវយវៈ ឈ្មោះថាប្រព្រឹត្តទៅក្នុងទិសឈាងទាំងឡាយ ព្រោះប្រារព្ធចំណែករបស់សរីរៈនោះៗប្រព្រឹត្តទៅ (ការមើលលក្ខណៈផ្សេងៗ ត្រូវបែរមុខទៅគ្រប់ទិស) ព្រោះហេតុនោះ បុគ្គលទាំងឡាយអ្នកចិញ្ចឹមជីវិតដោយវិជ្ជានោះ ទើបឈ្មោះថា**បែរមុខកាន់ទិសឈាងទាំងឡាយបរិភោគ** ។

បទថា **ឯវមារោចេសិ** សេចក្តីថា នាងបរិព្វាជិកា កាលពោលពាក្យជាដើមថា **ធម្មិកំ សមណា** ឈ្មោះថា ពោល (សរសើរ) គុណរបស់ព្រះ-សាសនាថា ជានិយ្យានិកធម៌ ។

ក៏មនុស្សទាំងឡាយ បានស្តាប់កថានោះហើយ នាំគ្នាជ្រះថ្លាក្នុងព្រះ-សាសនាប្រមាណ ៥០០ ត្រកូល ដូច្នេះឯង ។

ចប់អដ្ឋកថា សូចិមុខីសូត្រទី ១០

# ចប់សារីបុត្តសំយុត្ត

## ក្នុងសំយុត្តនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា សូត្រទី ១-៩

២-អដ្ឋកថា សូចិមុខីសូត្រទី ១០

# នាគសំយុត្ត

## អ ដ្ឋ ក ថា

### សុទ្ធកសូត្រទី ១

គប្បីជ្រាបវិនិច្ឆ័យក្នុង នាគសំយុត្ត សូត្រទី ១ ដូចតទៅនេះ ៖

[២៤៦] បទថា *អណ្ឌជា* ប្រែថា កើតក្នុងពង ។

បទថា *ជលាពុជា* ប្រែថា កើតក្នុងផ្ទៃ (កន្ទោបមកូន) ។

បទថា *សំសេទជា* ប្រែថា កើតក្នុងទីសើម ។

បទថា *ឱបបាតិកា* ប្រែថា កើត (រហ័ស) ដូចផុសឡើង ។

ក្នុងសូត្រនេះ ព្រះមានព្រះភាគត្រាស់ទុក ព្រោះជាហេតុកើតឡើងនៃរឿង ។ ព្រោះថា ភិក្ខុទាំងឡាយសន្ទនាគ្នាថា កំណើតនាគមានប៉ុន្មានហ្ន៎? លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់នឹងអធិប្បាយកំណើតនាគឲ្យជាក់ច្បាស់ ទើបត្រាស់សូត្រនេះ ដើម្បីឲ្យបុគ្គលទាំងឡាយនឿយណាយក្នុងកំណើតនាគ ។

ចប់អដ្ឋកថា សុទ្ធកសូត្រទី ១

# អ ដ្ឋ ក ថា

## សូត្រទី ២ ជាដើម

គប្បីជ្រាបវិនិច្ឆ័យក្នុង **សូត្រទី ២ ជាដើម** ដូចតទៅនេះ ៖

[២៤៨] បទថា **វោស្សដ្ឋកាយា** គឺ បណ្ដោយកាយដោយមិនគិតដល់អន្តរាយ ដែលកើតអំពីហ្វូពស់ ។

បទថា **ទ្វយការិនោ** ប្រែថា អ្នកមានប្រក្រតីធ្វើទាំងពីរយ៉ាង អធិប្បាយថា មានប្រក្រតីធ្វើទាំងកុសល និងអកុសល ។

បទថា **សចជ្ជ មយំ** សេចក្ដីថា ប្រសិនបើថ្ងៃនេះ យើងទាំងឡាយ ។

[២៥២] បទថា **សហព្យតំ ឧបប្បជ្ជតិ** សេចក្ដីថា ដល់ភាពជាអ្នក (នៅ) រួមគ្នា (សហភាព) ។ អកុសលជាបច្ច័យឲ្យបុគ្គលនោះកើតឡើងក្នុងកំណើតនាគនោះ (ចំណែក) កុសលជាបច្ច័យឲ្យនាគទាំងឡាយដែលកើតមកហើយសម្បូរណ៍ ។

[២៥៦] បទថា **អន្នំ** បានដល់ របស់ទំពាររបស់ស៊ី ។

បទថា **បានំ** បានដល់ ទឹកផឹកគ្រប់ប្រភេទ ។

បទថា **វត្ថំ** បានដល់ សំពត់ស្លៀក សំពត់ដណ្ដប់ ។

បទថា **យានំ** បានដល់ បច្ច័យដែលជួយក្នុងការដើរផ្លូវគ្រប់ប្រភេទ ចាប់តាំងពីឆ័ត្រ និងស្បែកជើង ។

បទថា **មាលំ** បានដល់ ផ្កាឈើគ្រប់ប្រភេទ ដូចជា ផ្កាម្លិះជាដើម ។

បទថា **គន្ធំ** បានដល់ គ្រឿងលាបគ្រប់ប្រភេទ ដូចជា ខ្លឹមចន្ទជាដើម ។

បទថា **សេយ្យំ ទេតិ អាវសថំ ទេតិ បទីបេយ្យំ ទេតិ**[១] សេចក្តីថា ឲ្យទីដេក មានគ្រែ និងតាំងជាដើម ឲ្យទីនៅអាស្រ័យ មានផ្ទះមួយជាន់ជាដើម (និង) ឲ្យឧបករណ៍ប្រទីប មានចង្កៀង និងប្រេងជាដើម ។

ក៏នាគទាំងនោះ ធ្វើសេចក្តីប្រាថ្នាដើម្បីឲ្យមានអាយុវែង មានពណ៌សម្បុរស្អាតល្អ និងច្រើនទៅដោយសេចក្តីសុខ ហើយឲ្យទានទាំង ១០ យ៉ាងនេះ ទើបកើតក្នុងភពនាគនោះ ហើយសោយសម្បត្តិនោះឯង ។

បទដ៏សេសគ្រប់សូត្រ ក៏មានន័យងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា សូត្រទី ២ ជាដើម

## ចប់នាគសំយុត្ត

### ក្នុងសំយុត្តនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា សុទ្ធកសូត្រទី ១ ២-អដ្ឋកថា សូត្រទី ២ ជាដើម

---

១ បាលីអដ្ឋកថា សេយ្យាវសថបទីបេយ្យំ ។

# សុបណ្ណសំយុត្ត

## អ ដ្ឋ ក ថា

### សុទ្ធកសូត្រទី ១

[២៥៨] គប្បីជ្រាបវិនិច្ឆ័យក្នុង សុបណ្ណសំយុត្ត ដូចតទៅនេះ ៖

គ្រុឌទាំងឡាយហៅថា សុបណ្ណ ព្រោះស្លាបមានពណ៌ល្អ ។ សូត្រទី ១ ក្នុងសុបណ្ណសំយុត្តនេះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុក ព្រោះជាហេតុកើតឡើងនៃរឿង តាមន័យដំបូងនុ៎ះឯង ។

ចប់អដ្ឋកថា សុទ្ធកសូត្រទី ១

# អ ដ្ឋ ក ថា

## ហរតិសូត្រទី ២

[២៥៩] បទថា ហរន្តិ ប្រែថា ឆាបយកទៅ ។ ក៏គ្រុឌទាំងនោះ កាលនឹងឆាប ក៏នឹងអាចឆាបតែពួកនាគដែលមិនស្មើនឹងខ្លួន ឬដែលស្មើនឹងខ្លួន (ប៉ុណ្ណោះ) (តែ) មិនអាចឆាបពួកនាគដែលប្រណីតជាងខ្លួន ឡើងទៅបាន ។

ក៏ឈ្មោះថា នាគ ដែលគ្រុឌឆាបយកទៅមិនបាន មាន ៧ ពួក គឺ នាគដែលមានជាតិខ្ពស់ជាង មួយពួក , នាគកម្ពលអស្សតរ មួយពួក , នាគ-ធតរដ្ឋ មួយពួក , នាគដែលនៅក្នុងមហាសមុទ្រសត្តសីទន្តរៈ មួយពួក , នាគដែលនៅលើផែនដី មួយពួក , នាគដែលនៅត្រង់ភ្នំ មួយពួក , នាគដែលនៅក្នុងវិមាន មួយពួក ។

បណ្ដានាគទាំងនោះ នាគដែលជាជលាពុជៈកំណើតជាដើម ខ្ពស់ជាងនាគដែលជាអណ្ឌៈកំណើតជាដើម នាគដែលជាជលាពុជៈកំណើតជាដើមទាំងនោះ ដែលគ្រុឌទាំងនោះ ឆាបយកទៅមិនបាន ។ ចំណែកនាគពួកកម្ពលអស្សតរ ជានាគសេនាបតី គ្រុឌទាំងឡាយឃើញនាគទាំងនោះក្នុងទី

ណាទីមួយហើយ ក៏មិនអាចនឹងចាប់យកទៅបាន ។ នាគជាតវជ្ជ ជានាគរាជា

សូម្បីនាគជាតវជ្ជទាំងនោះ គ្រុឌពួកណាក៏មិនអាចនឹងចាប់យកទៅបាន ។

ចំណែកនាគពួកណា នៅក្នុងមហាសមុទ្រសត្តសីទន្តរៈ គ្រុឌពួកណា ក៏មិនអាចនឹងចាប់យកនាគទាំងនោះទៅបាន ព្រោះហេតុដែលនរណាៗ មិនអាចនឹងធ្វើឲ្យញាប់ញ័របានក្នុងទីណាៗ (ក្នុងមហាសមុទ្រសត្តសីទន្តរៈនោះ) ។

ចំពោះពួកនាគដែលនៅតាមផែនដីជាដើម នឹងមានឱកាសដែលគេចលាក់ខ្លួន ដូច្នោះ គ្រុឌទើបមិនអាចនឹងចាប់យកនាគទាំងនោះទៅបាន ។

ចំណែកនាគពួកណានៅលើខ្នងរលកក្នុងមហាសមុទ្រ ដែលមានសភាពស្មើគ្នា ឬប្រណីតជាងគ្រុឌ គ្រុឌមិនអាចចាប់យកនាគទាំងនោះទៅបាន ។ បទដ៏សេស មានន័យដូចពោលហើយក្នុងនាគសំយុត្តនុ៎ះឯង ។

ចប់អដ្ឋកថា ហារតិសូត្រទី ២

## ចប់សុបណ្ណសំយុត្ត

### ក្នុងសំយុត្តនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា សុទ្ធកសូត្រទី ១ ២-អដ្ឋកថា ហារតិសូត្រទី ២

# គន្ធព្វកាយសំយុត្ត

## អ ដ្ឋ ក ថា

## សុទ្ធកសូត្រទី ១

[២៦៤] គប្បីជ្រាបវិនិច្ឆ័យក្នុង គន្ធព្វកាយសំយុត្ត ដូចតទៅនេះ ៖

បទថា មូលគន្ធេ អធិវត្ថា សេចក្តីថា ដើមឈើណាមានក្លិននៅត្រង់ឫស ទេវតាអាស្រ័យដើមឈើនោះកើត ។ ក៏ដើមឈើសូម្បីទាំងអស់នោះ រមែងសម្រេចប្រយោជន៍ដល់ទេវតាទាំងនោះ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យដូចគ្នានេះឯង ។

បទថា គន្ធគន្ធេ បានដល់ ក្លិន បណ្តាក្លិន មានក្លិនកើតអំពីឫសជាដើម ។

ក៏ចំណែកទាំងអស់ មានឫសជាដើមរបស់ដើមឈើណា មានក្លិន ដើមឈើនោះឈ្មោះ គន្ធៈ ក្នុងទីនេះ ត្រង់ក្លិនរបស់ដើមឈើដែលមានក្លិននោះ ។ ទេវតាស្ថិតនៅត្រង់ដើមឈើដែលមានក្លិននោះ ។ ក្នុងទីនេះ ចំណែកទាំងអស់ មានឫសជាដើម រមែងសម្រេចប្រយោជន៍ដល់ទេវតាទាំងនោះឯង ។

ចប់អដ្ឋកថា សុទ្ធកសូត្រទី ១

# អ ដ្ឋ ក ថា

## មូលគន្ធទាតាសូត្រទី ៣

[២៦៦] បទថា *សោ ទាតា ហោតិ មូលគន្ធានំ* សេចក្តីថា គេជាអ្នកឲ្យទាន ក្លិនឫសឈើ មានក្លិនលំពាន់ជាដើម ។ គប្បីជ្រាបសេចក្តីក្នុងគ្រប់បទយ៉ាងនេះ ។

ក៏ទេវតាទាំងឡាយ (កាលនៅជាមនុស្ស) ឲ្យទាន ដែលមានផលដូចគ្នានឹងវត្ថុដែលឲ្យហើយ តាំងសេចក្តីប្រាថ្នា (ដែលនឹងបានមកទទួលផលទាននេះ) ទុក ដោយប្រការដូចពណ៌នាមកដូច្នេះ ។ ដើម្បីនឹងសម្តែង សូម្បីទានដែលឲ្យផលមិនដូចគ្នានឹងវត្ថុដែលឲ្យនោះ ព្រះមានព្រះភាគទើបត្រាស់វត្ថុទាន ១០ យ៉ាងទុក មានជាដើមថា *សោ អន្នំ ទេតិ* (បុគ្គលឲ្យបាយ) ។ បទដ៏សេសក្នុងគ្រប់សូត្រ ក៏មានន័យងាយទាំងនោះឯង ។

ចប់អដ្ឋកថា មូលគន្ធទាតាសូត្រទី ៣

## ចប់គន្ធកាយសំយុត្ត

### ក្នុងសំយុត្តនេះមាន ០២ អដ្ឋកថា

១-អដ្ឋកថា សុទ្ធកសូត្រទី ១ ២-អដ្ឋកថា មូលគន្ធទាតាសូត្រទី ៣

# វលាហកសំយុត្ត

## អ ដ្ឋ ក ថា

## ទេសនាសូត្រទី ១

[២៧០] គប្បីជ្រាបវិនិច្ឆ័យក្នុង *វលាហកសំយុត្ត* ដូចតទៅនេះ ៖

បទថា *វលាហកកាយិកា* បានដល់ ទេវតាដែលអណ្តែតទៅក្នុងអាកាស ដែលកើតឡើងក្នុងពួកទេព នាមថា *វលាហកៈ* ។

បទថា *សីតវលាហកា* បានដល់ ទេវតាវលាហកៈ (ទេវាពពក) ដែលបណ្តាលឲ្យកើតភាពត្រជាក់ ។

សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នានេះឯង ។

ចប់អដ្ឋកថា ទេសនាសូត្រទី ១

# អ ដ្ឋ ក ថា

## សូត្រទី ១៣-៥២

[២៧៧] *បទថា* ***ចេតោបណិធិមន្វាយ*** *សេចក្តីថា អាស្រ័យការតាំងចិត្ត ។*

*បទថា* ***សីតំ ហោតិ*** *សេចក្តីថា ភាពត្រជាក់ណាមានក្នុងវស្សានរដូវ និងហេមន្តរដូវ ភាពត្រជាក់នោះ មានរដូវជាសមុដ្ឋាននោះឯង ។ ចំណែកភាពត្រជាក់ ដែលត្រជាក់ខ្លាំងជាងភាពត្រជាក់ទាំងឡាយ និងភាពត្រជាក់ដែលកើតឡើងក្នុងគិម្ហន្តរដូវណា ភាពត្រជាក់នោះ ចាត់ជាភាពត្រជាក់ដែលកើតឡើងដោយអានុភាពរបស់ទេវតា ។*

ចប់អដ្ឋកថា សូត្រទី ១៣-៥២

# អ ដ្ឋ ក ថា

## សូត្រទី ៥៣

[២៧៨] បទថា ឧណ្ហំ ហោតិ សេចក្តីថា ធាតុក្តៅក្នុងគិម្ហន្តរដូវណា ធាតុ ក្តៅនោះ ជាធាតុក្តៅប្រក្រតី (ធម្មតា) ទុំះឯង មានរដូវជាសមុដ្ឋាន ចំណែកធាតុក្តៅដែលមានសូម្បីក្នុងរដូវក្តៅ និងធាតុក្តៅ ដែលមានក្នុងរដូវត្រជាក់ ឈ្មោះថា ជាធាតុក្តៅដែលកើតឡើងដោយអានុភាពរបស់ទេវតា ។

ចប់អដ្ឋកថា សូត្រទី ៥៣

# អ ដ្ឋ ក ថា

## សុត្រទី ៥៤

[២៧៩] *បទថា* ***អព្ភំ ហោតិ*** *សេចក្ដីថា មានមណ្ឌបពពក (ក្រុមពពក) ។ សួម្បីក្នុងសូត្រនេះ ពពកដែលបង្កវស្សានឡើងក្នុងវស្សានរដូវ (រដូវភ្លៀង) និងក្នុងសិសិររដូវ (រដូវរងារ) ជាពពកតាមប្រក្រតី (ធម្មតា) នុ៎ះឯង មានរដូវជាសមុដ្ឋាន ។*

*ចំណែកពពកក្រាស់ ក្នុងរដូវមានពពកនុ៎ះឯង ដែលបិទបាំងព្រះចន្ទនិងព្រះអាទិត្យ ធ្វើឲ្យងងឹតតិចតួច អស់វេលា ៧ សប្ដាហ៍ និងពពកក្នុងខែ ៥ ខែ ៦ ឈ្មោះថា ពពកដែលកើតឡើងដោយអានុភាពរបស់ទេវតា ។*

ចប់អដ្ឋកថា សុត្រទី ៥៤

# អ ដ្ឋ ក ថា

## អត្ថវលាហកសូត្រទី ៥៥

[២៧៩] បទថា *វាតោ ហោតិ* សេចក្ដីថា ខ្យល់តាមប្រក្រតីដែលបក់មកពីទិសខាងជើង និងទិសខាងត្បូងជាដើម ដែលមានក្នុងរដូវនោះ នេះជាខ្យល់មានរដូវជាសមុដ្ឋានទុំះឯង ចំណែកខ្យល់កម្លាំងដែលបក់ទម្លាយដើមឈើជាដើម និងខ្យល់ដែលកើតឡើងខុសរដូវកាល ខ្យល់ដទៃនេះឈ្មោះថាខ្យល់ ដែលកើតដោយអានុភាពទេវតា ។

ចប់អដ្ឋកថា អត្ថវលាហកសូត្រទី ៥៥

# អ ដ្ឋ ក ថា

## វាតវលាហកសូត្រទី ៥៦

[២៨១] បទថា ទេវោ វស្សតិ សេចក្តីថា ភ្លៀងដែលធ្លាក់រហូតអស់ ៤ ខែ ក្នុងរដូវភ្លៀង ក៏មានឧតុជាសមុដ្ឋាននោះឯង ។ ចំណែកភ្លៀងជោគជាំដែលធ្លាក់ក្នុងរដូវភ្លៀង និងភ្លៀងក្នុងខែ ៥ ខែ ៦ ឈ្មោះថា កើតឡើងដោយអានុភាពទេវតា ។

ក្នុងសេចក្តីនោះ មានរឿងនេះជាតួយ៉ាង ៖

បានឮមកថា វស្សវលាហកទេវបុត្រមួយអង្គ ទៅរកព្រះថេរៈដែលខីណាស្រព ដែលចាំវស្សានៅក្នុងកុដិឈើក្រីស្នា ហើយបានឈរខាងក្រៅ ។

ព្រះថេរៈសួរថា អ្នកជាអ្នកណា ?

ខ្ញុំគឺ វស្សវលាហកទេវបុត្រ លោកម្ចាស់ ។

ជ្រាបថា ដោយអំណាចចិត្តរបស់អ្នក ធ្វើឲ្យភ្លៀងធ្លាក់បានឬ ?

ត្រូវហើយ លោកម្ចាស់

ពួកអាត្មា ចង់ឃើញ

លោកម្ចាស់នឹងទទឹកជាមិនខាន លោកម្ចាស់

ជុំពពកធំ ឬសំឡេងរន្ទះ មិនប្រាកដឡើយ ពួកយើងនឹងទទឹកបាន យ៉ាងណា ?

លោកម្ចាស់អំណាចចិត្តរបស់ខ្ញុំ ធ្វើឲ្យភ្លៀងធ្លាក់បាន សូមនិមន្តលោកម្ចាស់ចូលបណ្ណសាលាចុះ

ប្រពៃហើយ ទេវបុត្រ ព្រះថេរៈទទួលពាក្យហើយលាងជើង ចូលកាន់បណ្ណសាលា ។ កាលព្រះថេរៈនោះកំពុងចូលទៅ ទេវបុត្រក៏ច្រៀងចម្រៀងមួយបទ ហើយលើកដៃឡើង ។ ពេលនោះមានជុំពពកមួយជុំ តាំងឡើងជុំវិញស្ថានទីប្រមាណ ៣ យោជន៍ (ធ្វើឲ្យកើតភ្លៀង) ព្រះថេរៈទទឹកខ្លួនពាក់កណ្តាល ចូលទៅកាន់បណ្ណសាលា ។

មួយ៉ាងទៀត ឈ្មោះថា ភ្លៀងនេះ នឹងឈប់ធ្លាក់ក៏ព្រោះហេតុ ៨ ប្រការ គឺ ព្រោះអានុភាពរបស់នាគ ១ ព្រោះអានុភាពរបស់គ្រុឌ ១ ព្រោះអានុភាពរបស់ទេវតា ១ ព្រោះមានឧតុជាសមុដ្ឋាន ១ ព្រោះមារបណ្តាល ១ ព្រោះកម្លាំងឫទ្ធិ ១ ព្រោះមេឃប្រល័យកប្ប (ពពកដែលញ៉ាំងកប្បឲ្យវិនាស) ១ ។

ចប់អដ្ឋកថា វាតវលាហកសូត្រទី ៥៦

# ចប់វលាហកសំយុត្ត

## ក្នុងសំយុត្តនេះមាន ០៦ អដ្ឋកថា

១-អដ្ឋកថា ទេសនាសូត្រទី ១
២-អដ្ឋកថា សូត្រទី ១៣-៥២
៣-អដ្ឋកថា សូត្រទី ៥៣
៤-អដ្ឋកថា សូត្រទី ៥៤
៥-អដ្ឋកថា សូត្រទី ៥៥
៦-អដ្ឋកថា សូត្រទី ៥៦

# វច្ឆគោត្តសំយុត្ត

## អ ដ្ឋ ក ថា

## វច្ឆគោត្តសំយុត្ត

[២៨២-៣១២] *គប្បីជ្រាបវិនិច្ឆ័យក្នុង **វច្ឆគោត្តសំយុត្ត** ដូចតទៅនេះ ៖*

*បទថា **អញ្ញាតេ** ប្រែថា ព្រោះមិនដឹង ។*

*គប្បីជ្រាបអត្ថក្នុងគ្រប់បទ ដោយអំណាចជាតតិយាវិភត្តិដូចគ្នា ដូចពណ៌នាមកដូច្នេះ ។ ក៏បទទាំងនេះគ្រប់បទ ជាវេវចនៈនៃគ្នានិងគ្នាទុំះឯង ។*

*ក៏ឯក្នុងសំយុត្តនេះ គប្បីជ្រាបថា ព្រះមានព្រះភាគត្រាស់សូត្រទុក ១១ សូត្រ ត្រាស់វេយ្យាករណ៍ទុក ៥៥ វេយ្យាករណ៍ ។*

**ចប់វច្ឆគោត្តសំយុត្ត**

**ក្នុងសំយុត្តនេះមាន ០១ អដ្ឋកថា**

១-អដ្ឋកថា វច្ឆគោត្តសំយុត្ត

# សមាធិសំយុត្ត

## អ ដ្ឋ ក ថា

### សមាធិសមាបត្តិសូត្រទី ១

[៣១៣] គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១ នៃ សមាធិសំយុត្ត ដូចតទៅនេះ ៖

បទថា **សមាធិកុសលោ** សេចក្ដីថា ជាអ្នកឆ្លាតក្នុងការកំណត់អង្គយ៉ាងនេះគឺ បឋមជ្ឈានមានអង្គ ៥ ។

បទថា **ន សមាបត្តិកុសលោ** សេចក្ដីថា មិនអាចធ្វើចិត្តឲ្យរីករាយឲ្យអាច ហើយចូលឈានបាន ។

គប្បីជ្រាបបទដ៏សេសដោយន័យនេះ ។

ចប់អដ្ឋកថា សមាធិសមាបត្តិសូត្រទី ១

# អ ដ្ឋ ក ថា

## ឋិតិសូត្រទី ២

[៣១៤] គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ២ ជាដើម ដូចតទៅនេះ ៖

បទថា *ន សមាធិស្មឹ ឋិតិកុសលោ* សេចក្តីថា មិនឆ្លាតក្នុងការបញ្ឈប់ឈានទុកបាន គឺ មិនអាចនឹងបញ្ឈប់ឈានទុកបានដោយត្រឹមតែផ្ទាត់ ៧-៨ ម្រាមដៃ ។

ចប់អដ្ឋកថា ឋិតិសូត្រទី ២

# អ ដ្ឋ ក ថា

## ឋានសូត្រទី ៣

[៣១៥] *បទថា ន សមាធិស្ស ឋានកុសលោ សេចក្ដីថា មិនឆ្លាត ក្នុងការចេញចាកឈាន គឺ មិនអាចនឹងចេញបានតាមវេលាដែលកំណត់ទុក ។*

ចប់អដ្ឋកថា ឋានសូត្រទី ៣

# អ ដ្ឋ ក ថា

## កល្លិតសូត្រទី ៤

[៣១៦] *បទថា ន សមាធិស្មឹ កល្លិតកុសលោ សេចក្តីថា មិនឆ្លាតដែលគប្បីញុំាងចិត្តឲ្យរីករាយហើយ ធ្វើឲ្យអាច ។*

ចប់អដ្ឋកថា កល្លិតសូត្រទី ៤

# អ ដ្ឋ ក ថា

## អារម្មណសូត្រទី ៥

[៣១៧] *បទថា ន សមាធិស្មឹ អារម្មណកុសលោ សេចក្ដីថា មិនឆ្លាតក្នុងអារម្មណ៍ គឺ កសិណ ។*

ចប់អដ្ឋកថា អារម្មណសូត្រទី ៥

# អ ដ្ឋ ក ថា

## គោចរសូត្រទី ៦

[៣១៨] *បទថា ន សមាធិស្មឹ គោចរកុសលោ សេចក្ដីថា មិនឆ្លាត ក្នុងអារម្មណ៍របស់កម្មដ្ឋាន និងក្នុងទីមិនគោចរដើម្បីកិក្ខាចារ ។*

ចប់អដ្ឋកថា គោចរសូត្រទី ៦

# អ ដ្ឋ ក ថា

## អភិនីហារសូត្រទី ៧

[៣១៩] *បទថា ន សមាធិស្មឹ អភិនីហារកុសលោ សេចក្តីថា មិនឆ្លាតក្នុងការនាំកម្មដ្ឋានឲ្យខ្ពស់ឡើងទៅ ។*

ចប់អដ្ឋកថា អភិនីហារសូត្រទី ៧

# អ ដ្ឋ ក ថា

## សក្កច្ចការីសូត្រទី ៨

[៣២០] *បទថា ន សមាធិស្មឹ សក្កច្ចការី សេចក្តីថា មិនមែនអ្នកមានប្រក្រតីធ្វើដោយគោរព ដើម្បីធ្វើឈានឲ្យសម្រេចអប្បនា ។*

ចប់អដ្ឋកថា សក្កច្ចការីសូត្រទី ៨

# អ ដ្ឋ ក ថា

## សាតច្ចការីសូត្រទី ៩

[៣២១] *បទថា ន សមាធិស្មឹ សាតច្ចការី សេចក្តីថា មិនមែនជាអ្នកមានប្រក្រតីធ្វើជាប់តគ្នា ដើម្បីចេញចាកឈាន គឺ ធ្វើគ្រាខ្លះ ពេលខ្លះប៉ុណ្ណោះ ។*

ចប់អដ្ឋកថា សាតច្ចការីសូត្រទី៩

# អ ដ្ឋ ក ថា

## សប្បាយការីសូត្រទី ១០

[៣២២] *បទថា ន សមាធិស្ស សប្បាយការី សេចក្ដីថា មិនអាចនឹងធ្វើធម៌ដែលជាទីសប្បាយ គឺ ជាឧបការៈដល់សមាធិឲ្យបរិបូណ៌បាន ។*

ចប់អដ្ឋកថា សប្បាយការីសូត្រទី ១០

## ចប់សមាធិសំយុត្ត

### ក្នុងសំយុត្តនេះមាន ១០ អដ្ឋកថា


១-អដ្ឋកថា សមាធិសមាបត្តិសូត្រ
២-អដ្ឋកថា ឋិតិសូត្រ
៣-អដ្ឋកថា វុដ្ឋានសូត្រ
៤-អដ្ឋកថា កល្លិតសូត្រ
៥-អដ្ឋកថា អារម្មណសូត្រ
៦-អដ្ឋកថា គោចរសូត្រ
៧-អដ្ឋកថា អភិនីហារសូត្រ
៨-អដ្ឋកថា សក្កច្ចការីសូត្រ
៩-អដ្ឋកថា សាតច្ចការីសូត្រ
១០-អដ្ឋកថា សប្បាយការីសូត្រ

# មាតិកាធម៌


| ឈ្មោះធម៌ | | ទំព័រ |
|---|---|---|
| **ចូឡបណ្ណាសកៈ** | | |
| **ខន្ធសំយុត** | | |
| **អន្តវគ្គ** | | |
| អដ្ឋកថា អន្តសូត្រ | ទី ១ | ១ |
| អដ្ឋកថា ទុក្ខសូត្រ | ទី ២ | ២ |
| អដ្ឋកថា សក្កាយសូត្រ | ទី ៣ | ៣ |
| អដ្ឋកថា បរិញ្ញេយ្យសូត្រ | ទី ៤ | ៤ |
| អដ្ឋកថា សមណសូត្រ | ទី ៥ | ៥ |
| **ធម្មកថិកវគ្គ** | | |
| អដ្ឋកថា អវិជ្ជសូត្រ | ទី ១ | ៦ |
| អដ្ឋកថា វិជ្ជាសូត្រ | ទី ២ | ៧ |
| អដ្ឋកថា ធម្មកថិកសូត្រ | ទី ៣ | ៨ |
| អដ្ឋកថា ធម្មកថិកសូត្រ | ទី ៤ | ៩ |
| អដ្ឋកថា ពន្ធនសូត្រ | ទី ៥ | ១០ |
| អដ្ឋកថា បរិមុចចិត្តសូត្រ | ទី ៦–៩ | ១១ |
| អដ្ឋកថា សីលសូត្រ | ទី ១០ | ១២ |
| អដ្ឋកថា សុតវាសូត្រ | ទី ១១ | ១៤ |
| អដ្ឋកថា កប្បសូត្រ | ទី ១២ | ១៥ |

អដ្ឋកថា កប្បសូត្រ ទី ១៣ ១៦

**អវិជ្ជាវគ្គ**

អដ្ឋកថា សមុទយធម្មសូត្រ ទី ១ ១៧

**ភក្ខុឡវគ្គ**

អដ្ឋកថា កក្កុឡសូត្រ ទី ១ ១៨

**ទិដ្ឋិវគ្គ**

អដ្ឋកថា អជ្ឈត្តិកសូត្រ ទី ១ ១៩

អដ្ឋកថា ឯតំមមសូត្រ ទី ២ ២០

អដ្ឋកថា ឯសោអត្តសូត្រ ទី ៣ ២១

អដ្ឋកថា អានន្ទសូត្រ ទី ១០ ២២

**រាធសំយុត្ត**

**បឋមវគ្គ**

អដ្ឋកថា មារសូត្រ ទី ១ ២៤

អដ្ឋកថា សត្តសូត្រ ទី ២ ២៦

អដ្ឋកថា ភវនេត្តិសូត្រ ទី ៣ ២៧

អដ្ឋកថា បរិញ្ញេយ្យសូត្រ ទី ៤ ២៨

អដ្ឋកថា បឋម......សូត្រ ទី ៥ ២៩

**ទុតិយវគ្គ**

អដ្ឋកថា មារសូត្រ ទី ១ ៣០

អដ្ឋកថា មារធមិ៌សូត្រ ទី ២ ៣១

**អាយាចនវគ្គ**

អដ្ឋកថា អាយាចនវគ្គ ទី ៣ ៣២

**ឧបនិសិន្នវគ្គ**

អដ្ឋកថា ឧបនិសិន្នវគ្គ ទី ៤ ៣៣

**ទិដ្ឋិសំយុត្ត**

**សោតាបត្តិវគ្គ**

អដ្ឋកថា វាតសូត្រ ទី ១ ៣៤

អដ្ឋកថា ឯតំមមសូត្រ ទី ២–៤ ៣៦

អដ្ឋកថា នត្ថិទិន្នសូត្រ ទី ៥ ៣៨

អដ្ឋកថា ករោតោសូត្រ ទី ៦ ៤២

អដ្ឋកថា ហេតុសូត្រ ទី ៧ ៤៥

អដ្ឋកថា មហាទិដ្ឋិសូត្រ ទី ៨–១០ ៤៨

អដ្ឋកថា អន្តវាសូត្រ ទី ១១–១៨ ៥៩

**ទុតិយគមនាទិវគ្គ**

អដ្ឋកថា រូបីអត្តសូត្រ ទី ១៩ ៦១

អដ្ឋកថា អរូបីអត្តសូត្រ ទី ២០ ៦២

អដ្ឋកថា រូបីចអរូបីអត្តសូត្រ ទី ២១ ៦៣

អដ្ឋកថា នេវរូបីនា......សូត្រ ទី ២២ ៦៤

អដ្ឋកថា ឯកន្តសុខីសូត្រ ទី ២៣ ៦៥

អដ្ឋកថា ឯកន្តទុក្ខីសូត្រ ទី ២៤ ៦៦

**តតិយបេយ្យាល**

អដ្ឋកថា តតិយបេយ្យាល រួម ២៦ សូត្រ ៦៧

**ចតុត្ថបេយ្យាល**

អដ្ឋកថា ចតុត្ថបេយ្យាល ៦៨

**ឱក្កន្តសំយុត្ត**

អដ្ឋកថា ចក្ខុសុត្តាទិសូត្រ ទី ១–១០ ៦៩

**ឧប្បាទសំយុត្ត**

អដ្ឋកថា សូត្រទី ១–១០ ៧១

**កិលេសសំយុត្ត**

អដ្ឋកថា សូត្រទី ១–១០ ៧២

**សារីបុត្តសំយុត្ត**

អដ្ឋកថា សូត្រទី ១–៩ ៧៤

អដ្ឋកថា សុចិមុខីសូត្រ ទី ១០ ៧៥

**នាគសំយុត្ត**

អដ្ឋកថា សុទ្ធកសូត្រ ទី ១ ៧៩

អដ្ឋកថា សូត្រ ទី ២ ជាដើម ៨០

## សុបណ្ណសំយុត្ត


| | | |
|---|---|---|
| អដ្ឋកថា សុទ្ធកសូត្រ | ទី ១ | ៨២ |
| អដ្ឋកថា ហរតិសូត្រ | ទី ២ | ៨៣ |


## គន្ធព្វកាយសំយុត្ត


| | | |
|---|---|---|
| អដ្ឋកថា សុទ្ធកសូត្រ | ទី ១ | ៨៥ |
| អដ្ឋកថា មូលកន្ធាតាសូត្រ | ទី ៣ | ៨៦ |


## វលាហកសំយុត្ត


| | | |
|---|---|---|
| អដ្ឋកថា ទេសនាសូត្រ | ទី ១ | ៨៧ |
| អដ្ឋកថា សូត្រ | ទី ១៣-៥២ | ៨៨ |
| អដ្ឋកថា សូត្រ | ទី ៥៣ | ៨៩ |
| អដ្ឋកថា សូត្រ | ទី ៥៤ | ៩០ |
| អដ្ឋកថា សូត្រ | ទី ៥៥ | ៩១ |
| អដ្ឋកថា សូត្រ | ទី ៥៦ | ៩២ |


## វច្ឆគោត្តសំយុត្ត


| | | |
|---|---|---|
| អដ្ឋកថា វច្ឆគោត្តសំយុត្ត | | ៩៥ |


## សមាធិសំយុត្ត


| | | |
|---|---|---|
| អដ្ឋកថា សមាធិសមាបត្តិ | ទី ១ | ៩៦ |
| អដ្ឋកថា ឋិតិសូត្រ | ទី ២ | ៩៧ |
| អដ្ឋកថា វុដ្ឋានសូត្រ | ទី ៣ | ៩៨ |
| អដ្ឋកថា កល្លិតសូត្រ | ទី ៤ | ៩៩ |

អដ្ឋកថា អារម្មណសូត្រ ទី ៥ ១០០

អដ្ឋកថា គោចរសូត្រ ទី ៦ ១០១

អដ្ឋកថា អភិនីហារសូត្រ ទី ៧ ១០២

អដ្ឋកថា សក្កច្ចការីសូត្រ ទី ៨ ១០៣

អដ្ឋកថា សាតច្ចការីសូត្រ ទី ៩ ១០៤

អដ្ឋកថា សប្បាយការីសូត្រ ទី ១០ ១០៥